# ការសំភាសន៍របស់លោកយាយ ជា ស្រីនាង

កៈ អ្នកធ្វើការសំភាសន៍ដោយ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ជា ស្រីនាង

**<u>ការសង្ខេបរបស់លោកយាយ ជា ស្រីនាង</u>**

លោកយាយជា ស្រីនាងគាត់មានអាយុ ៦៤ឆ្នាំ ក្នុងឆ្នាំ ២០១៨ លោកយាយជា ស្រីនាងមានភេទ ស្រី លោកយាយជា ស្រីនាងមានទីលំនៅនាពេលបច្ចុប្បន្ន នៅឃុំកោះដាច់ស្រុកជ្រោយចង្វារក្រុងភ្នំពេញ លោកយាយជា ស្រីនាង មានកូនចំនួន ៤ នាក់ហើយកូនរបស់ខ្ញុំទាំងអស់សុទ្ធតែប្រុសទាំអស់ លោកយាយជា ស្រីនាង បានរៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ ១៩៧៩ លោកយាយជា ស្រីនាង គាត់មានប្ដីចំនួន ២ នាក់ម្នាក់លោកយាយជា
ស្រីនាងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងប្ដីទី២ហើយលោកយាយជា
ស្រីនាងគឺមិនបានបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងប្ដីទី១របស់គាត់នោះទេ។

កៈ
ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកយាយអំពីពង្សប្រវត្តិតតើលោកយាយអាយអនុញ្ញាត្តិអោយសំភាសន៍លោកយាយពង្សប្រវត្តិលោកយាយបានដែលទេ៕

ខៈ ចាសបាន ៕

កៈ ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍លោកយាយគឺជាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍លោកយាយឈ្មោះ ជា ស្រីនាង
ចឹងផ្ដើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់លោកយាយបាទេ???

ខៈ ចាសបាន នាងខ្ញុំឈ្មោះ ជា ស្រីនាង៕

កៈ ហើយឈ្មោះហៅក្រៅមានឈ្មោះអ្វីដែល???

ខៈ ចាសគឺគ្មានទេគឺមានតែឈ្មោះមួយនឹងគឺ ជា ស្រីនាងតែម្ដង៕

កៈ បាទចឹងលោកយាយឆ្នាំនឹងតើលោកយាយមានអាយុប៉ុន្មានឆ្នាំហើយលោកយាយ???

ខៈ ចាសឆ្នាំនឹងខ្ញុំមានអាយុ ៦៤ ឆ្នាំហើយចាស៕

កៈ ហ៊ឹមចឹងលោកយាយបានកើតនៅឆ្នាំណាដែលតើលោកយាយចាំដែលទេ???

ខៈ ចាសខ្ញុំអត់បានចាំនោះទេចាំតែខ្ញុំនឹងមានអាយុ ៦៤ ឆ្នាំហើយ៕

ក៖
បាទបើលសិនជាគិតជាឆ្នាំចន្ទ័គិតិអីតើលោកយាយអាចចាំដែលខ្លះដែលទេលោកយាយ???

ខ៖ ចាសគឺភ្លេចអត់ហើយចាគឺភ្លេចអត់ហើយចាសគឺចាំតែខ្ញុំនឹងមានឆ្នាំមមីរមានអាយុ ៦៤ ឆ្នាំតែប៉ុននឹងចាសគឺឆ្នាំមមីរមានអាយុ ៦៤ ឆ្នាំ៕

ក៖
ចឹងលោកយាយប្រហែលជាកើតនៅចន្លោះឆ្នាំ១៩៥០ជាងអីមែនដែលទេលោកយាយបាទប្រហែលជាកើតនៅចន្លោះឆ្នាំ១៩៥០ជាងអីខេចឹងលោកយាយមានទីកន្លែងកំណើតនៅកន្លែងណាដែលលោកយាយ???

ខ៖
ចាសទីកន្លែងកំណើតរបស់ខ្ញុំគឺនៅខាងកោះដាច់នឹងតែម្តងចាសគឺនៅមុខសាលារៀនមុខរនះនឹង៕

ក៖ បាទនៅភូមិអីស្រុកអីគេដែលលោកយាយ???

ខ៖
ចាសទីកន្លែងកំណើតគឺនៅកោះដាច់ស្រុកមុខកំពូលហាសភ្លេចបាត់ហើយនេះហោសស្រុកយើងស្រុកអីបងពាងពាងកោះដាច់ស្រុកមុខកំពូលចាសលូវនឹងហាសគឺនៅឃុំកោះដាច់ស្រុកជ្រោយចង្វារក្រុងភ្នំពេញចាសចង់ភ្លេចដល់តែមានគេប្រាប់ចាសហ៊ឹមចាសគឺនៅពីមុខភូមិរនេះឃុំកោះដាច់ស្រុកខេត្តកណ្តាលរួចមកដល់លូវនឹងគេក៏បានកាត់មកជាសង្កាត់កោះដាច់ខណ្ឌឬស្សីកែវរាជធានីភ្នំពេញវិញពីព្រោះលូវនឹងគេបានកាត់ចូលខណ្ឌជ្រោយចង្វារហើយចឹងនៅទៅកន្លែងនឹងកាត់ចូលក្រុងភ្នំពេញហើយ៕

ក៖ បាទចឹងលោកយាយមានក្រុមគ្រួសារប៉ុន្មាននាក់ដែលលោកយាយ???

ខ៖ ចាសខ្ញុំមានកូនចំនួន ៤ នាក់ហើយកូនរបស់ខ្ញុំទាំងអស់សុទ្ធតែប្រុសប្រុស៕

ក៖ ចឹងលោកយាយមានចាំឈ្មោះកូនរបស់លោកយាយទាំងអស់ដែលរីទេលោកយាយ???

ខ៖ ចាសចាំកូនរបស់ទី ១ គាត់មានឈ្មោះចិត្រ ចាសឈ្មោះពេញ កូនរបស់ទី ២ គាត់មានឈ្មោះឈុន ឡេង ចាសហើយកូនរបស់ទី ៣ គាត់មានឈ្មោះឈុន អេង ហើយកូនរបស់ទី ៤ គាត់មានឈ្មោះ ម៉េង អៀង៕

ក៖
បាទចឹងលោកយាយមានបានចាំពីសាច់រឿងរបស់កូនលោកយាយដែលពួកនៅកាល់ពីក្មេងក្មេងខ្លះដែលទេលោកយាយ???

ខ៖
ចាសចាំកាល់នៅពីក្មេងកូនរបស់ខ្ញុំពួកគាត់ខំទៅរៀនហើយធ្វើការទាំងអស់គ្នាហើយនៅពេលមិនបានទៅរៀនទេគឺនៅចិញ្ចឹមសត្វជ្រូកចាសគឺបិននឹងហើយនៅពេលដែលកូនរបស់ខ្ញុំទៅចិញ្ចឹមសត្វជ្រូកបានលុយខ្លះមកគឺពួកគាត់ទៅរៀនខាងប៉ូលិសទៅចាស៕

ក៖
បាទអរគុណច្រើនលោកយាយចឹងនៅពេលនឹងតើលោកយាយមានបានចាំអំពីឈ្មោះឪពុកម្តាយរបស់លោកយាយដែលរឺទេលោកយាយ???

ខ៖ ចាសចាំឪពុកបង្កើតរបស់ខ្ញុំគាត់មានឈ្មោះតា ជា ហើយម្តាយរបស់ខ្ញុំគាត់មានឈ្មោះយាយយ៉ម ចាស៕

ក៖ ហ៊ឹម បាទចឹងឪពុកម្តាយរបស់គាត់មានអាយុប៉ុន្មានឆ្នាំហើយលោកយាយ???

ខ៖
ហ៊ឪពុកម្តាយរបស់ខ្ញុំគឺពួកគាត់បានស្លាប់អស់ហើយទាំងពីជំនាន់យើងបានបែកពោលពតនៅកំឡុងពីឆ្នាំ១៩៧៩ មកចាសគឺពួកគាត់បានស្លាប់នៅក្នុនជំនាន់នឹងចាស៕

ក៖
ចឹងឪពុកម្តាយរបស់លោកយាយពួកគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតតែម្តងមែងដែលលោកយាយ???

ខ៖
ចាសឪពុកម្តាយរបស់លោកខ្ញុំពួកគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតតែម្តងគឺគាត់បានស្លាប់ដោយតែអត់មានអីសំរាប់ហូបគឺអត់មានបាយអត់ទឹកចឹងទៅនិយាយរួមឪពុកម្តាយរបស់ខ្ញុំពួកគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតនឹងគឺដោយតែដាច់ពោះអត់បាយតែម្តងគឺគាត់មិនបានស្លាប់រឿងអ្វីនោះទេគឺគាត់ស្លាប់ដោយសារគាត់ទាំងពីហែវចឹងទៅចាស៕

ក៖
ចឹងលោកយាយចាំថានៅពេលដែលពួកទាំងពីបានស្លាប់នឹងមានប៉ុន្មានដែលទេលោកយាយ???

ខ៖ គាត់នៅក្នុងជំនាន់នឹងគឺគាត់មានអាយុ ៦៧ រឺក៏ ៦៨
ចាសឪពុករបស់ខ្ញុំនឹងគាត់មានអាយុ ៧០
ឆ្នាំជាងហើយចាសហើយគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតកាល់នៅក្នុងឆ្នាំ១៩៧៩
នឹងតែម្តងចាសគឺ ១៩៧៨ រឺក៏ ១៩៧៩ នឹងចាស៕

ក៖
បាទហើយចឹងលោកយាយមានបានចាំអំពីឈ្មោះរបស់ឪពុករបស់ឪពុកហើយនឹងម្តាយរបេ

ស់ម្ដាយលោកយាយដែលរឺទេលោកយាយបានន័យថាជាម្ដាយរបស់ម្ដាយលោកយាយគឺជាជីដូនជីតា???

ខ៖ ចាសចាំខាងឪពុករបស់ខ្ញុំឪពុករបស់គាត់មានឈ្មោះតា ជន់
ហើយម្ដាយរបស់គាត់មានឈ្មោះយាយ សិម រួចហើយម្ដាយខាងខ្ញុំគាត់មានឈ្មោះយាយ មី
ហើយខាងឪពុករបស់ខ្ញុំគាត់មានឈ្មោះ តា ម៉ៅ ចាស៕

ក៖ ចឹងតើលោកយាយមានបានចាំថាគាត់មានអាយុរបស់ពួកគាត់ដែលរឺទេលោយាយ???

ខ៖
ចាសគឺមិនបានចាំនោះទេដោយសារពួកគាត់ចាស់ចាស់ពេកហើយហេហេហាចាសចាំបានតែឈ្មោះទេ៕

ក៖ចឹងលោកយាយមានបានចាំពីទីកន្លែកកំណើតរបស់ពួកគាត់ដែលរឺទេលោកយាយតើពួកគាត់បានកើតនៅឯណាដែលលោកយាយ???

ខ៖ ចាសទីកន្លែកកំណើតរបស់ពួកគាត់និយាយពីខាងម្ដាយរបស់គាត់ដែលហៅថា តា ម៉ៅ ហើយនឹង យាយ មី គឺគាត់នៅឯបឹងសាយាប់ឯនោះ៕

ក៖ បាទហើយពួកទីកន្លែកកំណើតរបស់ពួកគាត់ស្រុកអីខេត្តអីដែលលោកយាយ???

ខ៖ ចាសទីកន្លែកកំណើតរបស់ពួកគាត់និយាយពីខាងម្ដាយរបស់គាត់ដែលហៅថា តា ម៉ៅ ហើយនឹង យាយ មី
គឺគាត់នៅឯបឹងសាយាប់ឯនោះនៅឯខាងខ្សាច់កណ្ដាលហាសចាសខ្ញុំដូចជាចាំមិនសូវបានច្បាស់ខាងនឹងគឺខេត្ត កំពង់ចាម៕

ក៖
បាទចឹងលោកយាយមានគ្រួសារអ្វីទៀតដែលមានពាក់ពាន់ទៅនឹងឪពុកនឹងម្ដាយរបស់ដែលគាត់នៅក្នុងជំនាន់នឹងដែលរឺទេលោកយាយ???

ខ៖ ចាសដូចជាអត់មានទេចាស៕

ក៖
បាទចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់លោកយាយទៀតថាតើលោកយាយបាននិយាយទៅលោកយាយមានស្វាមីដែលរឺទេលោកយាយ???

ខ៖ ចាសមាន៕

ក៖ តើស្វាមីរបស់គាត់មានឈ្មោះអ្វីដែលទៅលោកយាយ???

ខ៖ ចាសស្វាមីរបស់ខ្ញុំគាត់មានឈ្មោះថា ឈឿន ឈោន៕

ក៖ បាទហើយស្វាមីរបស់គាត់មានអាយុប៉ុន្មានឆ្នាំហើយលោកយាយ???

ខ៖ ចាសស្វាមីរបស់ខ្ញុំគាត់មានអាយុ ៦៣ ឆ្នាំហើយចាសហើយស្វាមីរបស់ខ្ញុំគាត់មានអាយុប្អូនខ្ញុំចំនួនមួយឆ្នាំ៕

ក៖ ហើយស្វាមីរបស់លោកយាយគាត់មានទីកន្លែងកំណើតនៅទីកន្លែងដែលលោកយាយ???

ខ៖ ទីកន្លែងកំណើតស្វាមីរបស់ខ្ញុំគាត់នៅកំពង់រនេះនឹងដែល៕

ក៖ ទីកន្លែងកំណើតស្វាមីរបស់លោកយាយគាត់នៅកំពង់រនេះហើយនៅភូមិអ្វីហើយនឹងស្រុកអ្វីដែលលោកយាយ???

ខ៖ ភូមិរនេះហ៊ុមភូមិកោះដាច់ស្រុកមុខកំពូលនឹងនៅភូមិស្រុកជាមួយគ្នាចាស៕

ក៖ បាទចឹងលោកយាយមានបានចាំពីថ្ងៃដែលលោកយាយបានរៀបអាពាហ៍ពិពាហ៍របស់លោកយាយដែលរឺទេលោកយាយ???

ខ៖ ចាសអានឹងនៅពេលដែលបែកជំនាន់ពោលពតហើយចាសប្រហែលជាឆ្នាំ១៩៧៩ អីហើយបានខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងតានឹងពីព្រោះខ្ញុំមានអាយុច្រើនហើយនឹងចាស់ហើយនឹងហាសចាសកាល់ដែលនៅឆ្នាំ១៩៧៩ នឹងគឺខ្ញុំមានប្តីចំនួន ២ ណាពីព្រោះអីនៅជំនាន់ពោលពតនឹងគេបានយកប្តីរបស់នឹងយកទៅសំលាប់ចោលហើយនឹងបានប្តីពេលក្រោយនេះគឺក្រោយរួចពីជំនាន់ពោលពតនោះទេចាសខ្ញុំបានប្តីមុខនឹងគឺនៅក្នុងឆ្នាំ១៩៧៥ ចាសគឺឆ្នាំ១៩៧៥ ណារួចទៅពោលពតគេលេងទៅហើយពួកពោលពតគេក៏បានយកប្តីរបស់យកទៅសំលាប់ចោលបាត់ទៅចឹងបានថានៅពេលដែលយួនបានចូលមកទៅក៏ខ្ញុំបានប្តីដែលនៅក្រោយនឹងបាន ១ ចាសទៅ៕

ក៖ បាទហើយលោកយាយមានបានចាំថានៅពេលដែលបានរៀបអាពាហ៍ពិពាហ៍ប្តីរបស់លោកយាយតើលោកយាយចាំថាបានរៀបអាពាហ៍ពិពាហ៍នៅ ថ្ងៃ ណាហើយនឹង ខែ ណាដែលរឺទេលោកយាយ???

ខ៖ ចាសគឺខ្ញុំមិនបានចាំទេគឺភ្លេចអស់ហើយចាំតែថាបានរៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ ១៩៧៩

នឹងពីព្រោះអីយួនបានចូលមកហើយយួនបានរំដោះយើងយកបានបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងតានឹងទៅហើយយើងហើយដែលនៅជំនាន់មុខនឹងគឺជាជំនាន់១៩៧៥ ចាសគឺនិយាយពីប្ដីមុខហាសតាំងពីឆ្នាំ ១៩៧៥ ហើយើនៅពេលដែលឆ្នាំ១៩៧៧ គេក៏បានវៃចោលចាសគឺជាទាហ៊ានទាហ៊ានគេយកទៅវៃចោលចឹងទៅហើយខ្ញុំក៏ក្លាយទៅជាស្រីមេម៉ាយឯងហើយពេលនឹងតានឹងក៏យកតានឹងទៅចាស៕

កៈ
បាទចឹងនៅពេលដែលលោកយាយបានរៀបអាពាហ៍ពិពាហ៍ដែលជាស្វាមីរបស់លោកយាយនឹងថាតើលោកយាយបានបានរៀបអាពាហ៍ពិពាហ៍នឹងដោយស្មាក់ចិត្តរឺក៏មាននាក់ដែលចង្ខំលោកយាយដែលលោកយាយ???

ខៈ
ចាសគឺយើងវេចង្ហាន់សង្ឃពីព្រោះយើងមេម៉ាយហើយណាស់ដល់វេចង្ហាន់សង្ឃដូចកាល់ពីព្រឹកមិញចឹងហាសតែកាល់ពីមុខគឺយើងបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវចាសតែប្ដីនឹងគឺអត់បានរៀបអាពាហ៍ពិពាហ៍នោះគ្រាន់តែបានវេចង្ហាន់សង្ឃពីព្រោះអីយើងចាស់ចាស់អស់ហើយ៕

កៈ
បាទចឹងលោកយាយបានរៀបអាពាហ៍ពិពាហ៍ដោយសេចក្ដីស្រលាញ់មែនដែលទេលោកយាយ???

ខៈ
ចាសនិយាយទៅគឺបានរៀបអាពាហ៍ពិពាហ៍នឹងដោយសេចក្ដីស្រលាញ់ស្មោះហើយនឹងចិត្តខ្លួនឯងចាសនិយាយទៅគឺគ្មាននាក់មកបង្ខំខ្ញុំនោះទេចាស៕

កៈ
ចាទហើយនៅពេលដែលលោកយាយបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីរបស់លោកយាយទីកន្លែងណាដែលហើយនៅស្រុកអ្វីហើយភូមិអ្វីដែលលោកយាយ???

ខៈ
ចានៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីរបស់ខ្ញុំនោះគឺខ្ញុំបានរៀបអាពាហ៍ពិពាហ៍នៅផ្ទះរបស់យើងនឹងគឺនៅឃុំកោះដាច់តែម្ដងគឺភូមិរនេះ៕

កៈ បានរៀបអាពាហ៍ពិពាហ៍ឃុំរនេះនឹងនៅភូមអ្វីស្រុកអ្វីដែលទៅលោកយាយ???

ខៈ
ហ៊ឹមនៅបានរៀបអាពាហ៍ពិពាហ៍ឃុំរនេះនឹងនៅភូមគឺនៅភូមិកោះដាច់ស្រុកមុខកំពូលខណ្ឌឬស្សីកែវរាជធានីភ្នំពេញ៕

ក៖
បានចឹងលោកយាយបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីរបស់បានប៉ុន្មានឆ្នាំហើយលោកយាយហើយលោកយាយកំពុងតែរស់នៅជាមួយគ្នារឺក៏យ៉ាងមិចដែលលោកយាយ???

ខ៖ ចាសនៅបច្ចុប្បន្ននឹងគឺខ្ញុំកំពុងរស់នៅជាមួយគ្នាទេចាស៕

ក៖
បាទចឹងអរគុណច្រើនលោកយាយសំណួរដែលខ្ញុំចង់សួរទៅកាន់លោកយាយទៀតថាតើនៅពេលដែលលោកយាយនៅក្នុងជំនាន់រហូតមកដល់សព្វថ្ងៃនឹងតើលោកយាយមានបានចេះភាសាអ្វីក្រៅពីភាសាខ្មែររបស់យើងដែលរឺទេលោកយាយ???

ខ៖ ចាសគឺអត់ចេះផងគឺចេះតែភាសាខ្មែរនឹងតែម្តង៕

ក៖
បាទចឹងតើនៅជំនាន់នឹងតើលោកយាយរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែលលោកយាយ???

ខ៖ ចាសនៅជំនាន់នឹងគឺខ្ញុំរៀនបានត្រឹមថ្នាក់ទី ៩ ហើយខ្ញុំរៀនថ្នាក់ទី ៩ គឺខ្ញុំមើលអក្សរមិនចង់ដាច់ផងចាសហេហេហេតែគ្រាន់តែចេះតែថ្នាំថ្នាំទៅណាតែបើលអោយមើលអក្សររួលចឹងទៅម៉ងគឺខ្ញុំមើលមិនដាច់នោះទេចាសនៅពេលដែលខ្ញុំទៅលក់ថ្នាំខ្មែរអីចឹងទៅគឺខ្ញុំថ្នាំតាមជួរអីចឹងទៅហាសហើយគេបាបហៅយ៉ាងមិចមិចចឹងទៅហើយយើងក៏ធ្វើតាមចឹងទៅហាសចេះតែនឹងទៅហេហេហេ៕

ក៖
បាទអរគុណច្រើនលោកយាយចឹងនៅក្នុងជំនាន់នឹងតើលោកយាយគឺសិស្សពូកែរឺក៏ខ្សោយរឺក៏ជាសិស្សមធ្យមដែលលោកយាយ???

ខ៖
ចាសនៅជំនាន់នឹងខ្ញុំគឺជាសិស្សមធ្យមដោយសារគេបានដាក់អោយខ្ញុំជាសិស្សមធ្យមចាស៕

ក៖ បាទចឹងលោកយាយគឺជាសិស្សមធ្យមពូកែខាងភាសាអីគេដែលលោកយាយ???

ខ៖
ចាសនិយាយទៅគឺពូកែជាគេគឺភាសាខ្មែរនឹងតែម្តងពីព្រោះគេនិយាយថាខ្ញុំពូកែជាគេគឺភាសាខ្មែរហើយគេដាក់អោយតែខ្មែរនឹងតែមួយនិយាយទៅខ្មែរនឹងម៉ងចាស៕

ក៖
បាទចឹងលោកយាយរៀននៅជំនាន់នឹងតើលោកយាយរៀននៅសាលាណាវិញដែលលោកយាយ???

ខ៖ ចាសនៅជំនាន់នឹងខ្ញុំរៀននៅសាលាកោះដាច់៕

ក៖
បាទសាលាកោះដាច់ហើយសាលានឹងមានឈ្មោះអ្វីដែលទៅលោកយាយជាវិទ្យាល័យរឺក៏យ៉ាងមិចដែលលោកយាយ???

ខ៖ ហេសនៅជំនាន់នឹងគឺជាសាលាបថមគឺមិនមានជាវិទ្យាល័យអីនោះទេចាសអាថ្នាក់ទី១២បានគេហៅថាខ្នាតធំចាសចង់ភ្លេចបាត់ហើយហេសអានឹងធំហើយហើយទី៩នឹងធំហើយហេហេហេអត់ទេពីព្រោះអីទី៥ ឬទី៦នឹងគឺធំហើយចាស៕

ក៖
ចាទហើយនៅដែលលោកយាយសាលាតើលោកយាយមានបានចាំថាមានមិត្តដែលស្និតស្នាលដែលជាមិត្តល្អរបស់លោកយាយដែលរឺលោកយាយ???

ខ៖
ហ៊ឹមភ្លេចហើយក្មួយអើយមិត្តនៅដល់សព្វថ្ងៃម៉ាដែលស្និតស្នាលនៅគឺពួកគាត់នៅឆ្ងាយឆ្ងាយដែលគឺគេនៅជើងជើងឯនោះចាសគឺឆ្ងាយ៕

ក៖ បាទហ៊ីពួកគាត់មានគ្រួសារទាំងគ្នាហើយមែនដែលលោកយាយ???

ខ៖
ចាសគឺមានទាំងអត់គ្នាហើយគឺគេមានកូនមានទាំងចៅហើយខ្លះទៀតក៏បានស្លាប់អស់ខ្លះទៀតដែលទៅចាសគឺជំនាន់ពោលពតហើយមានខ្លះទៀតគេក៏បានទៅតាមប្ដីរបស់គេទៅហើយមានខ្លះទៀតគឺនៅជំនាន់ពោលពតគេបានយកទៅវៃចោលអស់ខ្លះទៀតចឹងទៅចាសនិយាយគឺមានមិត្តដែលស្និតស្នាលនឹងគឺនៅតែបន្តិតបន្តិចតែប៉ុននឹង

ក៖
បាទហើយចឹងសំណួរដែលខ្ញុំចង់សួរលោកយាយបន្ថែមទៀតថាតើលោកយាយនៅពេលដែលលោកយាយរៀននៅសាលាថាតើលោកយាយមានចេះលេងឧបករណ៍ភ្លេងអ្វីផ្សេងអ្វីទៀតដែលរឺទេលោកយាយ???

ខ៖
ចាសគឺអត់ចេះទេចាសគឺអត់តែម៉ងមកពីរៀនគឺខ្ញុំមកកៃត្បាញពីព្រោះម្ដាយរបស់ខ្ញុំគឺក្រម្ដាយក្រចឹងមានតែខំប្រឹងជួយធ្វើម្ដាយចូលកៃត្បាញហើយដាក់បាយអោយជ្រូកចឹងទៅហើយយើងឆាអាក្រលិងឈ្យូកនឹងគឺចូលធ្វើអោយគេហាសគឺជួយឆាអាក្រលិងឈ្យូកអោយគេចឹងទៅបាន១គីឡូរចឹងទៅពីព្រោះនៅជំនាន់នឹងគេបានតែ ២កាត់ រឺក៏បាន តែ៣កាត់
នឹងហើយគេហៅតែម៉ាហាប់ចឹងទៅគឺធ្វើម៉ាចុងចឹងទៅដែលបានមកពីការឆាអាក្រលិងឈ្យូកនឹងចឹងការ់ដែលខ្ញុំនៅរៀននឹងដូចឹសឹងតែមិនបានរៀនបានប៉ុន្មាននោះទេចាសថ្នាក់ទី ៩

គឺខ្ញុំមើលអក្សរមិនចង់ដាច់នោះទេដឹងតែថាដល់ម៉ោងគឺខ្ញុំរត់មកផ្ទះវិញចាសហើយបានមកដល់ផ្ទះវិញគឺមកជួយធ្វើការផ្ទះម្ដាយពីព្រោះអីម្ដាយរបស់ខ្ញុំក្រអីចឹងហាសហើយម្ដាយរបស់ខ្ញុំគាត់បានហានដើមចេក ២ រឺក៏ ៣
កញ្ជ្រងហើយមកដល់ផ្ទះវិញក៏នោមប្អូនប្អូនមកជាន់ក្បាល់ក្បៀនយកមកអោយសត្វជ្រូកស៊ីចាសហើយបើលខ្ញុំមិនជួយម្ដាយរបស់ខ្ញុំគឺគ្មាននាក់ជួយគាត់នោះទេពីព្រោះម្ដាយរបស់ខ្ញុំគាត់ក្រចឹងកាល់ដែលខ្ញុំនៅរៀននឹងក៏មិនសូវបានដែលចាសឡើងតែថ្នាក់ទេតែមើលមិនចង់ដាច់អក្សរទេចាសហោហោហោងថ្នាក់ច្រើនណាស់តែមើលអក្សរមិនសូវដាច់ទេតរតែកំប្រឹងមើលហើយចេះតែមើលមើលទៅហើយសុំដូចល្ងរមិនព្យាយាមទៀតចាសបានតែលក់ថ្នាំខ្មែរនឹងដូចជូរនឹងជូរនឹងចេះតែថ្នាំហើយនឹងចេះតែតាមគេតាមនឹងទៅចាសចេះតែតាមនឹងបណ្ដាលបណ្ដាលនឹងទៅហាស៕

ក៖
បាទចឹងនៅពេលដែលលោកយាយទៅរៀនតើលោកយាយមានអ្វីជាមធ្យោបាយសំរាប់ទៅរៀនដែលរឺទេលោកយាយ???

ខ៖
ចាសគឺនៅពេលដែលខ្ញុំទៅរៀនគឺខ្ញុំជិះកងដោយសារគេចាសហើយពេលគេជិះចឹងទៅគឺយើងឈររងចាំគេជួលកាល់យើងបានទៅជាមួយគេចឹងទៅហើយជួលកាល់ក៏មិនបានទៅជាមួយនឹងគេចឹងទៅចាសហើយក៏រត់ទៅក្រោយគេចឹងទៅចាសគឺដើររត់ដើររត់តាមផ្លូវក្រោយចឹងទៅវាលឿនចាសហើយប្រសិនជាគេនឹងចិត្តទៅគេក៏អោយយើងជិះទៅចាសហើយនៅពេលដែលកងគេបានខូចយើងនឹងក៏ដើរទៅចាមានតែប៉ុននឹងគ្រាន់តែថាយើងនឹងឈររង់ចាំគេសិនទៅចាសគិតចឹងពីព្រោះអីយើងវាអត់ពេកហាសចាសកាល់នៅជំនាន់នឹងនៅពេលគេមានកង់មួយមួយក្មួយអើយគឺវានឹងអស្ចារ្យណាស់ចាសមិនដូចនៅជំនាន់ល្ងរនឹងទេម៉ូតូល្មមល្មមអីគឺគេមិនចង់ជិះណាកាល់នៅជំនាន់អត់ទេបានកង់មួយមួយគឺខ្លាំងណាស់៕

ក៖
បាទហើយនៅពេលដែលគេអត់អោយលោកយាយជិះកង់ចឹងទៅលោកយាយកុំប្រឹងដើរទៅរៀនគឺឆ្ងាយណាស់បាទចឹងនៅពេលដែលលោកយាយបានដើរទៅរៀននឹងថាតើពីផ្ទះរបស់លោកយាយទៅដល់សាលារៀនមានប្រវែងប្រហែលជាប៉ុន្មានគីឡូរដែលទៅលោកយាយ???

ខ៖ ចាសកាល់ដែលខ្ញុំដើរទៅរៀននឹងគឺវាឆ្ងាយដែលនឹងហាសប្រហែលជា ២
គីឡូរជីអីនឹងចាសឆ្ងាយដែលនឹងហាសប្រហែលជា ២
គីឡូរជីចាសដើរម៉ាណាម៉ាណីប៉ុនតែយើងដើរនឹងគឺយើងមានផ្លូវកាត់សំរាប់ដើរទៅណាប្រសិនជាយើងដើរផ្លូវត្រង់វាមានរយះពេលយូរចឹងទៅយើងក៏ដើរទៅតាមផ្លូវក្រោយតែម៉ងទៅចាសគឺដើរផ្លូវកាត់គឺវាលឿនបន្តិចចាស៕

ក៖
បាទចឹងនៅពេលដែលនៅក្នុងជំនាន់នឹងគឺដើរទៅរៀនហើយក៏គ្មានអ្វីសំរាប់ជិះគឺឈរវង់ចាំដោយសារគេដើម្បីលោកយាយអាចបានទៅរៀននឹងគេបាទចឹងលោកយាយមានភាពពិបាក់អីទៀតទេដែលនៅក្នុងជំនាន់នឹងដែលលោកយាយ???

ខ៖
ចាសគឺវាពិបាក់ម្ដាយនឹងឪពុករបស់ខ្ញុំនឹងក្រណាក្នុយគឺពួកគាត់ពេតហាសហើយដល់ពេលដែលក្រចឹងពេតទៅគឺគាត់ទាំង២បានចិញ្ចឹមសត្វជ្រូកហើយគឺគាត់ទាំង២ជួយធ្វើអីចឹងហាសនិយាយរួមទៅគឺគាត់ទាំង២ឈ្នួលគ្នាហើយមកយើងវិញកាល់ដែលចខ្ញុំបានទៅរៀននឹងគឺខ្ញុំរៀនសូត្រមិនបានដិកដល់ដោយសារតែយើងនឹងបានមកជួយធ្វើការងារគាត់ទាំង២ហើយអោយបានរីកចំរើនការងារទៅអោយយើងនឹងបានហូបចុមខ្លះខ្លះហើយក៏បានលុយខ្លះនឹងទៅរៀនសូត្រនឹងគេហើយនៅពេលដែលដល់សាលារៀននោះគឺរៀនខ្ញុំមានតែចំនួនតែ ៥ កាក់អីនឹងពីព្រោះដែលនៅក្នុងជំនាន់នោះ ៥
កាក់គឺវាមានចំនួនច្រើនខ្លាំងណាស់ចាសដែលគាត់ទាំង២បានអោយទៅនឹងចាសហើយក៏មិនបានដូចលូវនឹងដែលរាប់រយរាប់ពាន់នោះទេចាសហើយនៅពេលដែលបានប្រាក់ចំនួន ៥
កាក់ចាយបានចំនួន១ថ្ងៃទៅហើយការចាយគឺបានទាំងព្រឹកហើយនឹងល្ងាចទៅចាសពីព្រោះអីគាត់វាអត់ចាស៕

ក៖
បាទចឹងនៅក្នុងជំនាន់នឹងលោកយាយហ៊ឹមម្ដាយនឹងឪពុករបស់លោកយាយគឺជាអ្នកផ្គត់ផ្គង់លោកយាយទៅសាលារៀនបាទហើយហ៊ឹមចឹងនៅពេលដែលលោកយាយទៅសាលារៀនហើយត្រូវបានម្ដាយនឹងឪពុករបស់លោកយាយគាត់ជាអ្នកផ្គត់ផ្គង់លោកយាយទៅសាលារៀនតើគាត់ទាំង២បានផ្គត់ផ្គង់លោកយាយយ៉ាងដូចម្ដេចដែលទៅលោកយាយ???

ខ៖ ចាសគាត់ទាំង២បានផ្គត់ផ្គង់យើងបានលុយតែប្រាក់ចំនួន ៥
កាក់នឹងទៅរៀនចឹងទៅហើយមកវិញចឹងទៅមានបាយនឹងម្ហូបល្អក៏ល្អចឹងទៅតែប្រសិនជាគ្មានម្ហូបដែលល្អក៏យើងនឹងអត់ទៅគឺពងទាចំនួន១គ្រាប់ចឹងទៅក៏ខ្ញុំបានចែកបានជាមួយនឹងបងប្អូនរបស់ខ្ញុំចឹងទៅចាសមួយ២នាក់ទៅគឺចែកគ្នាស៊ីទៅហាសចឹងគឺមិនសូវបានមានគ្មានម្ហូបល្អហើយនឹងឆ្ងាញ់នឹងគេនឹងឯងនោះទេចាសពីព្រោះអីយើងក្រពេកណាចាសហើយអ្វីដែលសំខាន់ជាគេនឹងគឺប្រហុកនឹងតែម្ដងចាសអោយតែមានប្រហុកនឹងគឺបានជ្រលុកនឹងត្រកួនចឹងទៅហើយគាត់ទាំង២ចេះតែពើតដាក់ស្ងោរអោយយើងចឹងទៅហាសនិយាយទៅអោយតែមានសំរាប់ស៊ីទៅហាសចុះប្រសិនជាយើងក្រអោយយើងធ្វើយ៉ាងប្រសិនជាយើងក្រចឹងចាសហើយមកជួយធ្វើការងារគាត់ទាំង២ទៀតចឹងទៅចាសគឺធ្វើអោយតែបានចឹងទៅចាស៕

ក៖
បាទអរគុណលោកយាយច្រើនលោកយាយចឹងសំរាប់ជំនាញអ្វីខ្លះដែលលោកយាយបានរៀននៅសាលារៀនតើលោកយាយមានជំនាញអ្វីខ្លះមកដល់សព្វថ្ងៃនឹងដែលលោកយាយ???

ខ៖
ចាសសព្វថ្ងៃដល់មុខរបស់នៃការចេះដឹងនឹងគឺវាគ្មានប៉ុន្មាននោះទេក៏ប៉ុនតែក្នុងការរកស៊ីសព្វថ្ងៃនឹងគឺខ្ញុំមានការលក់ដូរតែបន្តិចបន្តួចតែប៉ុននឹងទេណាកូនគឺមានលក់នៅក្នុងសាលារៀនដែលនៅក្មេងក្មេងដែលពួកគាត់ដែលរៀននឹងទៅហើយខ្ញុំលក់ចឹងទៅហើយក៏មានលក់ថ្នាំខ្មែរចឹងទៅហើយខ្ញុំក៏មានការត្បាញបន្តិចបន្តិចចឹងទៅចាសត្បាញបន្តិចបន្តិចចឹងរាល់ថ្ងៃចឹងទៅចាសគ្រាន់តែសំរាប់ចិញ្ចឹមបន្តិចបន្តិចចឹងទៅហាសតែប្រសិនជាអោយមានគឺគ្មានទេគ្រាន់តែសំរាប់ចិញ្ចឹមម៉ារស់ម៉ារស់ចឹងទៅហាស៕

ក៖ បាទចឹងលោកយាយត្បាញអ្វីដែលទៅលោកយាយ???

ខ៖
ចាសត្បាញក្រមារអីនឹងគឺត្បាញជាមួយនឹងអំបោះហើយត្បាញជាមួយសំពុតគឺជាសំពុតសឹងរបស់យើងនឹងហាសតែគេលក់អោយគេមួយដែលមានតំម្លៃចំនួន ២០០០០ មឺនរៀលហាសចាសហើយគេត្បាញនឹងគឺមានមានតំម្លៃចំនួន ២០០០០ មឺនរៀលចាសអានឹងគេហៅថាមួយក្បិនហើយនៅក្នុងមួយក្បិននឹងមានចំនួន២សំពុតហើយប្រសិនជាយើងយកទៅលក់អោយមោយយើងអាចទទួលបានប្រាក់ចំនួន ៩៥០០០មឺនរៀលចាសអានឹងអាល្អរបស់គេហាសតែប្រសិនជាអាអន់វិញយើងលក់បានប្រាក់តែចំនួន ៩០០០០មឺនរៀលតែប៉ុននឹងចាសរឺក៏មានពេលខ្លះបានតែប្រាក់ចំនួន៣៥០០មឺនរៀលអីចឹងទៅចាសតាមការយើងនឹងត្បាញល្អហើយនឹងតាមការយើងនឹងត្បាញមានអាអន់ចឹងទៅចាសតែលោកយាយចេះតែតស៊ូទៅពីព្រោះអីលោកយាយមានវយ័កាន់តែចាស់ហើយនឹងហាសហើយប្រសិនជាយើងទៅស៊ីឈ្នួលគេទៅគឺគ្មាននាក់ណាយកយើងទេគឺមិនបានទេចាសគឺយើងរកស៊ីបន្តិចបន្តិចចឹងទៅចាស៕

ក៖
បាទចឹងអរគុណច្រើនលោកយាយចឹងបញ្ហារបស់លោកយាយតើលោកយាយអាចប្រាប់ខ្ញុំបានទេអំពីជីវិតរបស់លោកយាយថាតើលោកយាយបានឆ្លងកាត់អំពីអ្វីខ្លះរបស់កូនចៅរបស់លោយាយហាស???

ខ៖
ចាសអានឹងដល់តែពីពេលនោះមកគឺវាបានធូរខ្លះហើយអាពេលដែលយ៉ាប់យើននឹងគឺនៅពេលដែលនៅក្នុងជំនាន់ពោលពតចាសហើយនៅពេលដែលនៅក្នុងជំនាន់ពោលពតដែល

វាខ្លាំងពេកទៅខ្ញុំមុននឹងសឹងតែរត់ពីរសេចក្តីស្លាប់ដែលនៅក្នុងជំនាន់ពោលពតហាសពី
ព្រោះអីខ្ញុំនឹងមានប្តីជាអ្នកធ្វើការងារជាទាហ៊ានដែលនៅក្នុងជំនាន់ពោលពតចាសគឺមុន
ពោលពតដែលប្តីរបស់ខ្ញុំគាត់បានធ្វើទាហ៊ានដែលគេមានពាក់អាវជាប៉ាវ៉ានឹងហាសចាស
ហើយពីឆ្នាំ ១៩៧៤ ហើយនឹងឆ្នាំ ១៩៧៥
គាត់បានធ្វើទាហ៊ានដែលនៅក្នុងជំនាន់ពោលពតគាត់ធ្វើការនៅក្នុងជំនាន់ពោលពតនឹង
ហើយដល់ពេលដែលឆ្នាំ ១៩៦៩ រហូតដល់ឆ្នាំ ១៩៧០
ចឹងទៅគាត់ក៏បានឈប់ធ្វើការងារនឹងទៅតែដល់ពេលគាត់បានឈប់ពីការងារនឹងហើយចឹ
ងទៅគឺយើងនៅតែមានប្រវត្តិដែលទាក់ទងនៅក្នុងជំនាន់ពោលពតដែលយើងបានធ្វើការ
ជាទាហ៊ានចឹងហាសហើយគេក៏បានចាប់ផ្តើមស្រាវជ្រាវតាមចាប់គាត់ដើម្បីយកគាត់នឹង
យកទៅសំលាប់ចោលចឹងទៅតាំងពីឆ្នាំ ១៩៧៧ ខែ ៨
នឹងគេយកគាត់នឹងយកទៅសំលាប់ចោលចឹងទៅហើយក៏បណ្តែកទឹកហាសហើយគេក៏បា
នបាញ់គាត់បណ្តែកទឹកទាំងហ្វូងទាំងហ្វូងចឹងទៅហើយគេក៏បានជីកអន់ណេ្តាហើយនៅពេ
លដែលយើងមិនព្រមចូលទៅក្នុងអន់ណេ្តានឹងគេក៏បានយកយើងទៅម៉ារឹងអូសចូលទៅមា
ត់កំពង់ចឹងទៅគេយកយើងទៅបាញ់ចោលចឹងទៅហើយក៏បណ្តែកទឹកចោលចឹងទៅហើយ
ក៏បណ្តែកទឹកធ្លាក់រហូតបានមកដល់ក្បាលការតូចនឹងហើយប្អូនរបស់ខ្ញុំក៏ពួកពោលពតវា
បានបាញ់ទំល្លាក់ចោលចឹងដែលចាសដែលនៅក្នុងជំនាន់ពោលពតហាសពីព្រោះអីយើង
បានធ្វើការងារអោយពួកពោលពតហាសចឹងទៅហើយនៅពេលដែលយើងខុសឈ្លោបអីចឹ
ងទៅគឺខុសឈ្លោបចឹងគឺគេមិនបាននិយាយអីច្រើននោះទេគឺគេយកយើងទៅបាញ់ចោល
តែម្តងចឹងបានថានៅពេលដែលនៅក្នុងជំនាន់ពោលពតនឹងហាសចាសបើលគិតទៅវិលវិ
ញវិលមកគឺវាចូលជុកពេកហាសគឺថាជីវិតរបស់ខ្ញុំនឹងគឺទ្រាំនឹងមិនសឹងចង់នឹងបាននោះទេ
ហាសក្មួយវាឈឺចាប់វាឈឺចាប់ត្រូវថាវាងាកតែចង់សំលាប់ឯងវាមិនបានទៅសួរនឹងព្យាយា
មរកយុត្តិធម៌អោយឯងថាយើងនឹងខុសពីរឿងអ្វីនោះគឺអត់ទេគឺវាដឹងតែថាមានកំហុសអីតែ
បន្តិចបន្តួចអីនឹងតែដល់ពេលល្ងាចអីតិចនឹងគឺវាចាប់ផ្តើមយកយើងនឹងទៅហើយតាមានកំ
ហុសអីតែបន្តិចបន្តួចអីនឹងតែដល់ពេលល្ងាចអីតិចនឹងគឺវាចាប់ផ្តើមយកយើងនឹងទៅហើយ
ចាសចឹងនៅពេលដែលពួកពោលពតដែលគេបានយកទៅនឹងគឺគេមិនបាននឹងត្រឡប់មកវិ
ញនោះទេចាសហើយវាក៏បានអួតប្រាប់យើងថាគឺយកយើងនឹងអោយយើងនឹងបានទៅជួប
ប្តីរបស់យើងហើយប្តីរបស់ធ្លាប់ធ្វើអ្វីពីមុខមកគឺប្តីរបស់គេនឹងបានកំពុងនឹងរងចាំនៅឯនោះ
ចឹងហើយបងឯងទៅមិត្តឯងទៅទៅណាសដល់មានណាក្មួយអើយគឺទៅងាប់គឺពួកពោលព
តគឺពួកវាបានយកយើងនឹងទៅបាញ់ចោលបានមិនបានពីយើង
៥០ម៉េត្រផងស្រាប់តែយើងបានលឺសូរគ្រាប់កាប់ភ្លើងដល់ពេលដែលបានលឺសូរគ្រាប់កាប់
ភ្លើងដល់ពេលដែលទៅមើលមនុស្សគឺយើងមិនបានឃើញមនុស្សនោះទេគឺយើងបានឃើ
ញតែស្បែងជើងហើយនឹងខោអាវចឹងទៅហាសចាសគឺយើងមិនបានឃើញមនុស្សនោះទេ
បានថាមកដល់ជំនាន់ខ្ញុំក្រោយនឹងទៀតគឺពួកពោលពតពួកវាបានតាមសំលាប់ខ្ញុំនឹងបានអ
ស្ចារ្យនៅពេលដែលពួកពោលពតនឹងវាតាមសំលាប់ខ្ញុំនឹងគឺពួកឃ្មួនវាមិនទាន់បានចូលមក
នោះទេចាសដល់ពេលចឹងយើងក៏ចាប់ផ្តើមរត់គេចពីពួកពោលពតនឹងហើយដល់ថ្ងៃនឹងខ្ញុំ

បានយល់សុប្តិនគឺខ្ញុំនិយាយជាពិតដូចជាអស់លោកគាត់បានមកប្រាប់ខ្ញុំថាអោយខ្ញុំនឹងចេញទៅក្រៅហើយនៅពេលដែលខ្ញុំបានចេញទៅក្រៅទៅមានមនុស្សលោកចេញមកនេះមកមានក្លិនធ្មេះធ្អាបណាស់ផ្ទះរបស់មនុស្សលោកហើយពេលនឹងខ្ញុំក៏បាននិយាយថាមនុស្សលោកនឹងធីនឹងហើយគេក៏បាននិយាយថាមកអោយលឿនមកស្អែកនឹងគេយកមនុស្សដើម្បីយកទៅសំលាប់ចោលហើយលគឺមនុស្សលោកចំនួន ៥០
គ្រួសារយកទៅដើម្បីសំលាប់ចោលហើយហើយខ្ញុំនឹងក៏មានអារម្មណ៍ហើយខ្ញុំក៏បាននិយាយថាមិចបងមិចបងហើយគេបាននិយាយថាមនុស្សលោកស្តោះទឹកមាត់មកហើយយើងមានប្រាជ្ញាមួយជីវិតគឺមិនចេះនឹងស្លាប់នោះទេចាសគឺនឹងត្រូវគេចផុតទាំងអស់ទោះមានរឿងអ្វីក៏ដោយនឹងត្រូវគេចផុតទាំងអស់ហើយខ្ញុំនឹងក៏ហាមាត់នឹងហើយស្តោះទឹកមាត់រួចថាម៉ោង
៣ល្ងាចនឹងគេនឹងតយកទៅសំលាប់ចោលហើយចាសហើយម៉ោង៣នឹងគេក៏បានមកប្រមូលគ្រួសារចំនួន៥០គ្រួសារមែនហើយក៏បានយកទៅសំលាប់ចោលយ៉ាងពិតប្រកុដមែនចាសដល់ពេលនឹងខ្ញុំនឹងក៏បានតវ៉ានឹងគេដែលហើយខ្ញុំក៏បានសួរគេថាបើលប្តីរបស់ខ្ញុំគាត់បានឈប់ធ្វើការតាំងពីឆ្នាំ១៩៧៩មកហើយហេតុអ្វីបានជាចង់យកខ្ញុំនឹងទៅទៀតចាសគឺអាម្នាក់ឈ្មោះអាសុវណ្ណហើយនឹងអាម្នាក់ឈ្មោះអាធឿនវាអោយសួរពុសសាំម៉ាវៃដែលនៅលើតុនឹងទៅគឺមានកាំភ្លើងនឹងទៅអាណាទុក្ខអោយឯងនៅក៏នៅទៅតែប្រសិនជាអាណាមិនបានទុក្ខអោយឯងនៅឯងត្រូវតែទៅចឹងហាសហើយខ្ញុំក៏បាននិយាយថាអើយប្រសិនជាបងឯងចង់យកខ្ញុំនឹងទៅសំលាប់ចោលហាសប្រសិនជាបងឯងគេអោយទៅកាន់ប្រទេសហើយបងឯងឡើងសោចរាជជំនោសគេក៏ទៅទៅពីព្រោះអីគេមិនបានធ្វើចឹងទេចឹងទៅប្រសិនជាបងឯងអាចលើកលេងអោយបានគួរណាបងឯងលើកលេងអោយទៅកុំយកពួកខ្ញុំនឹងយកទៅសំលាប់មនុស្សដូចជារូបខ្ញុំទៀតអីពីព្រោះអីខ្ញុំមិនបានមានកំហុសនោះទេចាសដល់ពេលចឹងទៅពួកអាពោលពតនឹងក៏បានវៃខ្ញុំតែម្តងចាសហើយពួកពោលពតនឹងវាបានវៃខ្ញុំនឹងមានចំនួន
៥រឺក៏៥កំផ្លៀងហាសពីព្រោះអីពួកពោលពតវាខឹងនឹងខ្ញុំដែលខ្ញុំនឹងបានថាអោយពួកវារួចហើយខ្ញុំក៏បានរួច១យប់នឹងមកហើយដល់ពេលស្អែកឡើងខ្ញុំក៏ចាប់ផ្តើមរត់បន្តទៀតហើយខ្ញុំតាមការហែលទឹកនោះគឺទឹកគួរដែលចេកនឹងដើរហែលកាត់ទន្លេរទៅចាសហែលកាត់ទន្លេរទៅដើរកាត់ក៏បានជួបទូរគេដែលមានត្រីហើយគេនឹងក៏បានអាណិតខ្ញុំគេក៏បានអោយខ្ញុំនឹងអំពារអំពារហើយក៏អោយខ្ញុំនឹងបានទោងគេទៅហើយ១ទៀតគេមិនបានអនុញ្ញត្តិអោយខ្ញុំនឹងឡើងទៅទូតរបស់គេនោះទេចាសគឺគេគ្រាន់អោយខ្ញុំនឹងបានទោងទូតរបស់គេនឹងពីទន្លេរនឹងទៅដល់ខាងឡើងចឹងទៅហើយខ្ញុំក៏បានទៅរស់នៅនៅឯវត្តខ្វល់ទៅចាសទៅបានបែកយួនហើយនៅពេលដែលខ្ញុំបានទៅរស់នៅវត្តហើយគឺពួកវាក៏បានទៅតាមរកខ្ញុំទៀតហាសដើម្បីមកសំលាប់ខ្ញុំហើយនៅពេលដែលពួកវាបានមកដល់ក្អួយអើយចាសប្រហែលជាម៉ោងជិត១០អីនឹងហាសដែលខ្ញុំបានមកដល់ព្រៃកយួននឹងហាសហើយនឹងព្រៃកតាពង់អីនឹងពីព្រោះអីគេបានអោយយកត្រីរួនអីនឹងមកដើម្បីមកធ្វើជាត្រីប្រហុកចឹងហាសដល់ពេលចឹងទៅគឺវាបានទៅចឹងទៅតាជ្រូកគាត់បាននិយាយថាកុំទាន់អាយកគ្នាទៅអីស្លាប់រឺក៏រស់គឺអោ

យគ្នាបានស៊ីបបរសិនទៅចាសពីព្រោះអីបបរនឹងវាពុះលូវនឹងហើយដល់ពេលចឹងទៅពួកពោលពតវាចេះតែចាំចាំទៅក្មួយអើយចាសគឺចាំរហូតដល់ម៉ោងរហូតម៉ោង ៣ រឺក៏ ៤ ស្រាប់តែពេលនឹយួនក៏បានមកហើយក៏បានទំលាក់គ្រាប់បែកផ្អើលពេញនឹងហើយក៏បានបែកសំបុកចឹងទៅគឺបែកសំបុកចឹងទៅក៏ខានយកខ្ញុំនឹងមកសំលាប់ទៀតមកចាសកុំអីខ្ញុំបានស្លាប់ដែលនៅក្នុងជំនាន់បាត់ហើយចាសមិនរស់ទេគឺខ្ញុំគេចលេងផុតហើយពីព្រោះអីពួកពោលពតវាបានមកយកខ្ញុំទៅដល់កន្លែងនឹងហើយចឹងហើយខ្ញុំគិតថាខ្ញុំនឹងស្លាប់ហើយពីព្រោះអីគឺខ្ញុំគ្មានកន្លែងនឹងគេចទៀតទេគឺអស់ហើយហើយខ្ញុំនឹងក៏បានទ្រាមខ្លួននឹងស្លាប់ហើយចាសតែខ្ញុំមានបុណ្យហើយទោះបីជាយ៉ាងណាក៏ដោយក៏ខ្ញុំមិនបានដឹងដែលពីព្រោះប្រទេសជាតិទៅជាយ៉ាងក៏ខ្ញុំមិនបានដឹងទៀតដែលពីព្រោះខ្ញុំគ្រាន់តែដឹងថាហើយនឹងដឹងគុណត្រូវថាប្រសិនបើលមិនបានមានយួនចូលនៅថ្ងៃនឹងទេគឺខ្ញុំនឹងបានស្លាប់បាត់ហើយតែលូវត្រង់ថាយួនយ៉ាងមិចហើយនឹងចិនយ៉ាងមិចគឺខ្ញុំមិនបានដឹងទេខ្ញុំដឹងតែតាមដំណើរដែលខ្ញុំបានរស់រានមានជីវិតរហូតបានមកដល់សព្វថ្ងៃនឹងគឺខ្ញុំនឹកដល់គុណរបស់គាត់ចាសតែលូវនឹងប្រសិនជាគាត់ចង់ធ្វើយ៉ាងមិចទៀតគឺខ្ញុំមិនបានដឹងទេពីព្រោះនេះជារឿងរបស់គាត់ទេគឺខ្ញុំសុំតែម៉ារួចខ្លួនហើយចាសគឺខ្ញុំអត់តាមឆ្លើយអីទៀតទេចង់អ្នកឯងចង់ថារឿងយ៉ាងមិចយ៉ាងមិចគឺជារឿងរបស់អ្នកឯងហើយខ្ញុំមិនដឹងទេខ្ញុំគ្រាន់តាដឹងថាមានគាត់ថ្ងៃនឹងគឺខ្ញុំនឹងស្លាប់បាត់ហើយចាសហើយខុសតែ១ម៉ោងក៏ខ្ញុំនឹងស្លាប់ដែលគឺអោយតែបបរនឹងបានស៊ីគឺខ្ញុំនឹងស្លាប់តែម្តងចាសតែសំណាងអីបបរនឹងវាចេះវាមិនទាន់បានពុះហាសដល់ម៉ោងប្រហែលជា៤អីនឹងយួនក៏បានទំលាក់គ្រាប់បែកហើយផ្អើលហើយក៏បានបែកសំបុកពួកពោលពតនឹងតែម្តងទៅចាសគឺខ្ញុំមានតែប៉ុននឹងចាស៕

ក៖
បាទចឹងអរគុណច្រើនលោកយាយចឹងនៅពេលដែលយួនរឺក៏វៀតណាមពួកគាត់បានទំលាក់គ្រាប់បែកចុះមកចឹងតើលោកយាយរស់នៅខេត្តណាដែលទៅលោកយាយ???

ខ៖
ចាសខ្ញុំរស់នៅខាងព្រៃកតាគង់ចាសគឺនៅខាងព្រៃកលៀបនៅខាងព្រៃកតាគង់នឹងនៅពេលដែលយួនបានចុះមកគឺខ្ញុំរស់កន្លែងនឹងតែម្តងពីព្រោះអីគេបានចុះតាមជួរនឹងតែម្តងចាសនៅនឹងកុំអីខ្ញុំស្លាប់ហើយគឺមិនរស់ទេខ្ញុំរួចនៅនឹងអាយួននៅនឹងពួកអានឹងរត់មកនៅនឹងហើយយើងនៅក្នុងក្លូកហើយយួននៅនឹងតែម្តងចាសគឺពួកដែលមានប៉ុន្មាននាក់នៅតែម្តងចាសគឺមិនទៅណានោះទេបានថាខ្ញុំចាំច្បាស់ចាំត្រង់ថាមិនខឹងមកដល់សព្វថ្ងៃនឹងមិចថាមិចយ៉ងាមិចគឺខ្ញុំមិនដឹងទេគ្រាន់តែនៅជំនាន់នឹងខ្ញុំគ្រាន់តែនឹកគុណពួកគាត់ថាប្រសិនបើលពួកគាត់មិនបានមកខ្ញុំនឹងស្លាប់ហើយចាសគឺខ្ញុំនឹកគុណតែប៉ុននឹងដល់ពេលលូវនឹងហាសគេចង់ធ្វើយ៉ាងមិចក៏ធ្វើទៅគឺជារឿងរបស់អស់លោកដែលជាអ្នកធ្វើខ្ញុំក៏មិនដឹងដែលហេហេហេ៕

ក៖
បាទចឹងនៅពេលដែលគេទំលាក់គ្រាប់ចុះមកចឹងតើលោកយាយនៅជំនាន់នឹងហើយលោកយាយមានបានរត់ទៅណាទៀតដែលរឺទេលោកយាយ???

ខ៖
ចាសគឺអត់មានរត់ទៅណាទៀតទេគឺខ្ញុំលេងរត់ទៀតហើយគឺខ្ញុំអាចមកផ្ទះបានហើយអានឹងសុខស្រួលហើយណាទៅដល់យួនចូលមកគឺខ្ញុំលេងភ័យនឹងស្លាប់ទៀតហើយពីព្រោះអីពួកពោលពតពួកវាបានបែកអស់ចឹងហាសគឺពួកវាបានបែកអស់ចឹងទៅគឺវាលេងតាមនឹងចង់សំលាប់ខ្ញុំទៀតហើយចឹងហើយវាត្រូវយើងត្រូវបានរត់ទៅពីព្រៃកតាគង់ទៅដល់កោះហើយបានបបួលម្ដាយហើយនឹងបងប្អូនរបស់ខ្ញុំមកនៅទៅកន្លែងនឹងវិញចាសគឺមកនៅដីកោះនឹងវិញហាសហើយយើងក៏ជញ្ជូលអីវ៉ាន់មកវិញមកចាសហើយយើងក៏បានសុខស្រួលរហូតមកដល់សព្វថ្ងៃនឹងទៅចាសហើយបានមកមួយជីវិតរបស់យើងចិញ្ចឹមកូនចៅមករហូតមកដល់ទៀតទៅហើយក៏បានកូនរៀនសូត្រចេះដឹងនឹងគេចឹងទៅរហូតដល់ទៀតចឹងមកនិយាយពីកូនរបស់ខ្ញុំរៀននឹងក៏មានភាពពីបាក់ក្ស័យអើយនិយាយទៅគឺក្រគឺខ្ញុំមិនបានអោយកូនទៅរៀនបានស្រួលដល់ពេលដែលកូនរបស់ខ្ញុំរៀនច្រើនចឹងទៅយើងនឹងក៏នាក់តែហត់នឿយច្រើនចឹងហាសហើយនឹងពីបាក់ពីព្រោះអីយើងនឹងធ្វើជាម្ដាយរបស់គេចឹងហាសតែបើលធ្វើយ៉ាងមិចបើលយើងជាអ្នកចង់អោយពួកវាទៅរៀនយ៉ាងដូចថ្មឹងចាសហើយកូនរបស់គឺពួកវាបានរៀនចប់ទាំងអស់ហើយនឹងពួកវាបានធ្វើការងារទាំងអស់គ្នាចាសចឹងមួយមួយខ្ញុំបានចំណាយអស់ច្រើនខ្លាំងណាស់ហើយខ្ញុំនឹងក៏មិនដែលបានមានសំពុតស្លៀកពាក់ល្អដូចលូវនឹងគេទេដឹងតែថាសំពុតស្លៀកពាក់ក្បាលនឹងក្តិតទល់នឹងគ្នាហើយចងភ្ជាប់នឹងគ្នាចាសពីព្រោះអីអានឹងវាមាំបន្តិចហើយនឹងក៏ស្លៀកទៅហើយអាណាស្តើងស្តើងយើងដាក់ចុះមកខាងក្រោមចឹងទៅទំរាំបានកូនមួយមួយនឹងរៀនបានចេះចេះចឹងទៅចាសគឺកូនរបស់ខ្ញុំរៀនបានចេះច្រើនចេះច្រើនគ្រប់គ្រប់គ្នាចាសគឺអត់មានចេះតិចទេចាសគឺចាប់គ្រប់គ្នាទាំងអស់ចាសបាក់ឌុបហើយខ្ញុំអោយរៀន៩ឆ្នាំបន្តទៀតរៀន៩ឆ្នាំបន្តទៀតគឺគ្រប់កូនទាំងអស់កូនចំនួន៣គឺរៀនបានទាំងអស់គឺបានទាំងនិយាយទៅក្ស័យយ៉ាប់ក្ស័យអើយគឺពីបាក់នឹងចិញ្ចឹមកូននឹងតែម្តងចាសអោយកូនរៀនចេះតែប្រសិនបើចិញ្ចឹមកូនអោយរកត្រីហើយចិញ្ចឹមកូនដើម្បីធ្វើសំសង់ចិញ្ចឹមកូន២០នាក់គឺមិនមានបញ្ហាអ្វីទាំងអស់តែប្រសិនជាអោយចិញ្ចឹមកូនអោយកូនដើម្បីអោយពួកគេបានធ្វើការងាររដ្ឋទាំង២ហើយនឹង៣នាក់គឺហត់ខ្លាំងណាស់ហត់ខ្លាំងណាស់ហត់ខ្លាំងណាស់ក្នុងជីវិតគឺរត់មិនរួចទេហត់ខ្លាំងណាស់តែខ្ញុំនឹងចេះតែតស៊ូរចាសចេះតែតស៊ូរទៅតែលូវនឹងខ្ញុំបានកូនរបស់ខ្ញុំពួកគាត់បានធ្វើប៉ូលិសទាំងគ្នាហើយគឺធ្វើបាន៣នាក់ហើយចឹងខ្ញុំបានធូរបន្តិចធូរគេមិនបានអោយលុយកាក់យើងទេតែធូរត្រូវថាគេរស់ដោយខ្លួនគេគឺយើងមិនបាច់ភ័យទៅនឹងចិញ្ចឹមគេចឹងហាសគេរស់ដោយខ្លួនគេទៅចាសគេគ្រាន់បានអោយយើងនឹងហូបហូបហើយមិនអោយហូបក៏អត់ទៅណាស់មិនតស៊ូរហើយមិនបានតត់ស្លុតអីដែលយើងចេះតែរកបន្តិចបន្តិចទៅចាស៕

កៈ
បាទចឹងសំណួរដែលខ្ញុំចង់សួរបក់ក្រោយទៅកាន់លោកយាយបន្តិចថាតើដែលនៅជំនាន់ដែលគេបានទំលាក់គ្រាប់ហើយលោកយាយបានមានជីវិតបានមកវិញហើយលោកយាយរត់មកស្រុកកំណើតវិញចឹងតើលោកយាយនៅតាមផ្លូវតើលោកយាយបានជួបពួកដែលនៅជំនាន់ពោលពតដែលពួកគាត់នៅតាមផ្លូវមានបានជួបលោកយាយទៀតដែលរឺទេលោកយាយ???

ខៈ
ចាសគឺអត់បានជួបនោះទេពីព្រោះអីពួកវាបានរត់អស់ទៅហើយពីព្រោះអីពួកវាខ្លាចហើយពួកវាបានឃើញគេទំលាក់គ្រប់បែកច្រើនចឹងទៅគឺពួលវាបានផ្រែវចេញទៅហើយមាននាក់បោះកាំភ្លើងចោលហើយមានអ្នកខ្លះទៀតក៏បានបោះខោអាវចោលហើយក៏មានអ្នកខ្លះទៀតក៏បានបោះស្បែកជើងចោលទៅចាសតាមពិតខ្ញុំក៏បានឃើញដែលគឺឃើញដើរកាត់តាមផ្លូវដែលគេបានមកតាមទូលនឹងហាសតែពួកវាក៏បានរតើអស់ទៅវាអស់មានអីដែលត្រូវនៅហើយនឹងសង្ងំអីនោះទេគឺអោយយើងនឹងបានឃើញពួកវាហើយវាទៅបានដល់ពេលនេះពួកនឹងវាឡើងទៅចឹងហាសគឺឡើងតាមភូមិចឹងទៅហើយយើងអាចរស់បានក៏ដោយសារមានពួកវៀតណាមគាត់បានចុះទៅចឹងហាសដូចមិចមិចចឹងខ្ញុំបានថាចឹងប្រសិនជាចង់ធ្វើយ៉ាងមិចទៀតគឺខ្ញុំមិនបានដឹងទៀតទេចាសដែលដឹងពេលនឹងខ្ញុំរស់រានមានជីវិតគឺដោយសារពួកវៀតណាមតែពេលនោះគាត់ចង់ធ្វើយ៉ាងមិចទៀតគឺខ្ញុំមិនបានដឹងទៀតទេចាសនឹងគឺជារឿងរបស់គាត់ហេហេហេ៕

កៈ
បាទចឹងអរគុណាច្រើនលោកយាយហើយនៅពេលដែលបានឃើញពួលពោលពតដែលនៅតាមផ្លូវចឹងតើពួកពោលពតគាត់មានបានធ្វើអ្វីទៅកាន់លោកយាយដែលរឺទេលោកយាយ???

ខៈ
ចាសគឺអត់បានជួបផងគឺពួកពោលពតពួកវាភ័យដែលចឹងហាសចាសនឹងហើយគឺវាភ័យហើយពួកពោលពតវាបានគេចពីយើងដែលចឹងហាសគឺពួកវាលេងហ៊ានហើយហើយពួកវាចេះតែគេចគេចទៅចាសថ្ងៃមុខនឹងខ្ញុំក៏បានមកជួបម្នាក់ចាសហ៊ាយគឺយូរឆ្នាំហើយចាសមានពេលមួយនឹងគឺជួបគេនឹងដោយសារវាក់អើនោះទេដោយខ្ញុំបានឃើញគាត់នឹងស្លៀកពាក់ទេចាសនៅពេលដែលខ្ញុំបានឃើញគាត់នឹងស្លៀកពាក់ចឹងទៅហើយខ្ញុំក៏បាននិយាយហាស្សរួចហើយនៅមានពាក់សំស្លៀកពាក់នឹងទៀតចឹងហាស្សរួចហើយយើងនឹងក៏បានរៀបរាបពីជំនាន់ពោលពតដែលពួកវាបានកាន់ពីកងនេះហើយនឹងកងនោះចឹងហើយខ្ញុំក៏បានស្រែកហៅប៉ូលិសអោយមកចាប់ពួកវាហើយពេលនឹងវាបានភ័យហើយវាក៏បានរត់ទៅបាត់ទៅចាសនឹងគឺជួបបានម្តងនឹងក្រៅពីនឹងគឺខ្ញុំលេងបានជួបពួកនឹងទៀតហើយចាសគឺលេងបានជួបពួកនឹងរហូតមកជួបនឹងគឺជួបដោយសារបានឃើញដោយសារពួកវាមានខោអាវនឹងចឹង

ហាសរួចពួកវាក៏បានរត់បាត់រហូតតាំងពីពេលនឹងមកហើយយើងក៏បានទទួលបានសេចក្តីតាំងពីនឹងរហូតបានមកដល់សព្វថ្ងៃនឹងមកចាសហើយក៏បានចិញ្ចឹមកូនហើយនឹងបានចិញ្ចឹមចៅហើយក៏បានអោយរៀនអោយសូត្រហើយបានធ្វើការងារចឹងទៅណាស់៕

កៈ
បាទចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់លោកយាយបន្ថែមទៀតថាតើនៅពេលដែលលោកយាយបានជួបគាត់ហេតុអ្វីបានជាគាត់បានរត់គេចពីលោកយាយទៅវិញចឹងលោកយាយ???

ខៈ
ចាសគឺនៅពេលដែលវាបានឃើញខ្ញុំវាក៏រត់គេចពីខ្ញុំតែម្តងចឹងទៅគឺខ្ញុំអត់ដឹងផងចាសប្រហែលគេបានខ្លាចខ្ញុំអីក៏មិនដឹងហេហេហេពីព្រោះអីខ្ញុំបានស្គាល់មុខគាត់ច្បាស់ណាស់ដែលបានទៅហៅខ្ញុំពីកន្លែងហើយនឹងយកមកសំលាប់នោះអើយដល់ពេលនឹងខ្ញុំក៏បាននិយាយទៀតថាហាសមិចវានៅមានជីវិតទៀតដល់ពេលចឹងទៅខ្ញុំក៏បានស្រែកហៅប៉ូលិសអើយជួយផងនេះហើយគឺពួកអាពោលពតប៉ូលិសអើយជួយផងនេះហើយគឺពួកអាពោលពតស្រាប់តែប៉ូលិសបានចុះមកដល់អាគាត់នឹងក៏បានរត់បាត់ទៅចាសហើយខ្ញុំមិនបានដឹងថាគាត់នឹងរត់ទៅដល់ណាទេគឺនៅកំពង់ដរព្រែកលែបនឹងហាសហើយខ្ញុំក៏លេងបានឃើញគាត់យគាត់ក៏បានរត់បាត់ទៅចាសពីព្រោះអីខ្ញុំនឹកក្នុងចិត្តហើយក៏បានច្បាស់ថាគាត់នឹងហើយដែលទៅយកខ្ញុំពីកន្លែងនឹងមកដើម្បីយកខ្ញុំនឹងទៅសំលាប់ចោលតែខ្ញុំមានសំណាងដែលពួកយួនបានចូលមកដល់ហើយពួកពោលពតក៏ខានយកខ្ញុំមកចាសកុំអីខ្ញុំនឹងបានស្លាប់បាត់ហើយក្មួយអើយគឺខ្ញុំនឹងមិនរស់នោះទេចាសហេហេហេ៕

កៈ
បាទចឹងតើលោកយាយមានបានចាំថាអ្នកដែលយកលោកយាយទៅដើម្បសំលាប់លោកយាយនឹងតើគាត់មានឈ្មោះអ្វីដែលទៅលោកយាយ???

ខៈ
ចាសខ្ញុំចាំគាត់នឹងមានទី១ឈ្មោះអាសុវណ្ណហើយទី២មានឈ្មោះអាធឿនហើយនឹងទី៣មានឈ្មោះថាអាផលចាសមានចំនួន៣នាក់នឹងហាសដែលជាមេអាពតនឹងហាសនឹងអ្នកដែលកាន់ម៉ាខាងកោះដាច់នឹងគឺវានឹងហើយដែលជាមេគេទាំងអស់ហើយវាដែលបញ្ជាថាទៅអោយយកមនុស្សណាមកសំលាប់ចោលនោះគឺជាវានឹងហើយគឺវាចាសគឺគ្មានអ្នកអាចនឹងប្រកែកបាននោះទេចាសក៏ប៉ុនតែក្មួយអើយក្មួយឯងដែលនៅវ័យក្មេងចឹងគឺមិនទាន់ដឹងទេតែប្រសិនបើលជាក្មួយឯងបានដឹងពីជំនាន់នឹងវិញបានគួរអោយអស្ចារ្យហាសក្មេងហ៊ឺមល្បាក់មក្មួយឯងនឹងណាហាសវាសឹងតែនៅជំនាន់ដែលពោលពតគឺវាមានគ្នាអំពិចអំពិចទៅណាគឺគ្នាធ្លាប់តែនៅភ្នំពេញដល់ពេលដែលចឹងទៅគ្នាក៏បានជិះកង់ចេញចឹងទៅហើយនៅពេលដែលជិះកង់ចេញចឹងទៅរួចហើយកង់នឹងក៏បានស៊ីផ្លេសនៅពេលដែលបានស៊ីផ្លេសនឹងយួនក៏បានចេញមកទាល់ចឹងទៅណាពីព្រោះអីប្រសិនបើលជាអាសុវណ្ណនឹងគេថាវៃហើយវៃរ

ហូតដល់ស្លាប់នៅមុខផ្ទះនឹងតែម្តងចាសហើយថានឹងផ្ញើនគេផ្លូវដែលគេជិះនឹងគេបានស៊ីផ្លេសអោយគេហើយដល់ពេលដែលគេបានស៊ីផ្លេសអោយគេចឹងទៅគេក៏បានហៅស្វរលិចហើយនឹងកើតចឹងទៅគឺសុទ្ធតែរៃនឹងស្នែរកាំភ្លើងគឺរៃសំលាប់ហើយម្តាយនឹងឪពុកចាសគឺគ្នានឹងកំលោះហើយនឹងបានថាក្មួយអើយដែលនៅក្នុងជំានាន់នោះក្មួយអើយប្រសិនជាយើងបានឃើញអំពីទេសភាពដែលនៅក្នុងជំនាន់ហាសហើយប្រសិនបើលប្រៀបធៀបគួរណាស់តែពួកកូនកូនទាំងអស់ធ្វើបាប់ម្តាយម្តាយគួរណាតែកូនកូននឹងបានមកគោរពម្តាយម្តាយហើយនឹងសង្ឃ៉ចិត្តបុណ្យជាមួយម្តាយម្តាយពីព្រោះអីឪពុកម្តាយដែលនៅក្នុងជំនាន់នឹងគឺសែនពិបាក់ចឹងហើយកូនកូនទាំងអស់គួរណាស់សង្ឃ៉ចិត្តបុណ្យនឹងជាមួយម្តាយម្តាយហើយកុំនឹងសង្ឃ៉ចិត្តបាប់ហើយនឹងកុំធ្វើបាប់ឪពុកម្តាយអីហើយនឹងសុំផ្តាំទៅកូនកូនទាំងអស់គ្នាផងណាចាស៕

ក៖
បាទអរគុណច្រើនណាស់លោកយាយហើយចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់លោកយាយទៀតតើថានៅពេលដែលជំនាន់ពោលពតចឹងថាតើលោកយាយមានភាពពិបាក់អ្វីខ្លះរបស់លោកយាយជួបនឹងបញ្ហាដែលពិបាក់ខ្លាំងបំផុត???

ខ៖
ចាសអ្វីដែលពិបាក់ខ្លាំងបំផុតសំរាប់ខ្ញុំនោះគឺថាគឺគ្មានអ្វីដែលពិបាក់ក្រៅពីអ្វីដែលពួកពោលពតមិនបានអោយខ្ញុំហូបតែម្តងណាក្មួយចាសបបរ១ខ្វះត្បោតហើយក្នុងខ្វះត្បោតនឹងមានតែអង្ករតែចំនួន១គីឡូនឹងចាសចឹងក្នុង១បោយនឹងនៅពេលដែលកូរទៅសឹងតែមិនបាន២ស្លាបព្រាផងនឹងដែលនៅក្នុង១បោយដែលបានមកពីសាច់អង្ករនឹងហាសគឺមិនបានមានពីសាច់អង្ករ២ស្លាបព្រាផងគឺហូតតែទឹកទេម្តងអស់មានគឺមានទឹកតែម្តងគឺមិនបានស្មើរទឹកបាយផងប្រសិនគិតទៅនៅពេលដែលជ្រត់ទឹកបាយគឺវាខាប់ជាបបរដែលពួកពោលពតអោយើងស៊ីផងនិយាយគឺសុទ្ធតែទឹកតែម្តងចឹងដូចវាដាំទឹកអោយយើងផឹកតែម្តងចាសហើយនៅក្នុង១របបរបស់យើងគឺមិនបាន២ស្លាបព្រាផងនឹងចាសហើយការហូបចុកគឺមិនបានគ្រប់គ្រាន់ហើយចំនែកដេកវិញគឺខ្ញុំមិនដែលបានដេកនឹងនឹងគេទេគឺដោយសារមានអារម្មណ៍ថាភ័យហើយដេកចេះតែភ័យពីព្រោះខ្លាចវាហៅចំឈ្មោះរបស់យើងនឹងហើយក៏មិនដឹងថាចំឈ្មោះគេនោះទេចាសចឹងការដេកក៏មានអារម្មណ៍ថាភ័យហើយចំនែកការដេកនឹងក៏មានអារម្មណ៍ថាភ័យដែលចាសហើយការហូបនឹងក៏មិនបានពគ្រាប់គ្រាន់ដែលចាសហើយព្រឹកព្រលឹមឡើងគឺវាអោយយើងធ្វលការពេញបន្ទុកហើយអោយយើងនឹងទៅកាប់ដី១០ម៉ែត្រ៥ជ្រុងហើយធ្លាក់ទៅដល់មាត់កំពង់អីនឹងគឺត្រូវតែកាប់អោយហើយតែប្រសិនបើលយើងកាប់មិនហើយទេគឺពួកវាមានផែនការធ្វើយើងទៀតហើយគឺអោយនឹងទៅលីចោបឈរដែលនៅនឹងមុខសហាករនឹងទៅចាសនឹងហើយមិត្តនារីឯងធ្វើការងារមិនបានគោរពបានត្រឹមត្រូវរបស់ផែនការដែលគេបានដាក់ទៅអោយមិត្តនារីឯងត្រូវតែលីចោបឈរនឹងពីព្រោះអីខ្ញុំនឹងបានដើរតាមមកនឹងគឺបងប្អូនដែលគេនៅខាងនឹងដែលគេជាអ្នកល្អនឹងគេក៏បានអោយខ្ញុំនឹងបានអោយចេកហើយនឹងពោតហើយនឹងល្ហុងអីនឹងដែលបានយកទៅហូបហើយគេបានយើ

ញហើយគេបានចាប់បានគេក៏បានអោយខ្ញុំនឹងទូររបស់របបនឹងដែលមានប៉េបោះនឹងមានចំនួន១បាវអាយើងតូចនឹងហាសអា១បាវដូចជាទាហ៊ានអង្គរនឹងហាសគឺគេបានអោយខ្ញុំនឹងទូរទាំងពីម៉ោង៩ព្រឹករហូតដល់ម៉ោង១ទើបគេអោយខ្ញុំនឹងឈប់ទូរចាសហើយនៅពេលដែលខ្ញុំឈប់ទូរហើយគេក៏បានអោយខ្ញុំនឹងស្រែកប្រាប់ទៅកាន់សហាករថាសូមកុំយកគំរូតាមខ្ញុំទៀតសូមកុំមិត្តមិត្តកុំយកគំរូតាមខ្ញុំពីព្រោះអីខ្ញុំមិនបានដើរតាមគោនិយោបាយរបស់បក្សចឹងបានខ្ញុំនឹងវាខុសចឹងសូមកុំយកគំរូតាមខ្ញុំហើយនៅពេលដែលខ្ញុំស្រែកហើយខ្ញុំស្មានតែគេនឹងអោយរបស់របបទាំងអស់នឹងអោយមកសំរាប់កូនរបស់ខ្ញុំស៊ីតែតែគេមិនបានអោយទៅកូនរបស់ខ្ញុំទេគឺគេបានយកទាំងនឹងគឺយកទៅស៊ីសំរាប់ខ្លួនគេដ៏ដែលចាសហើយគេក៏បានដាក់ផ្លែឈើទាំងអស់នឹងដាក់នៅពីខាងក្រោយកន្ទុយកង់គេជិះទៅបាត់ចាសហើយខ្ញុំនឹងកំទូរចង់ស្លាប់ហើយខ្ញុំក៏បានហូបរបស់របបទាំងអស់នឹងដែលចឹងបានថាគឺពិបាក់ណាស់ក្មួយអើយពីបាក់ហើយដែលនៅក្នុងជំនាន់នេះរស់រស់ពីជំនាន់នោះរស់តាំងទាំងពីបាក់ខ្លាំងណាស់ចាសកុំថានៅក្នុងជំនាន់នេះពិបាក់ក្មួយនៅក្នុងជំនាន់នោះគឺថាពិបាក់ជាង១០០ដងទៅទៀតតែខ្ញុំចេះតែតស៊ូរនៅក្នុងជីវិតទៅតស៊ូរអោយបានរស់តទៅមុខទៀតគឺត្រូវតែកំប្រឹងរស់ចាសហើយនឹងដើម្បីចិញ្ចឹមកូនចាសអោយកូនបានរៀនសូត្របានដឹងនឹងគេហើយនឹងអោយកូនមានមុខមានមាត់នឹងគេទៀតទៅចាសទោះកូនមិនបានស្គាល់ខ្ញុំក៏ខ្ញុំមិនបានទៅខឹងកូនរបស់ខ្ញុំដែលណាតែអោតែកូននឹងរស់បានស្រួលទៅចុះកុំអោយប្រពន្ធរបស់គេនឹងមានភាពពិបាក់ដូចនឹងរូបខ្ញុំទៀតចាសខ្ញុំបានគិតចឹងចាសនិយាយទៅគឺខ្ញុំមិនចង់បានអ្វីអ្វីពីកូនកូនរបស់ខ្ញុំនោះទេចាសអោយតែបានសុខបិននឹងគឺវាល្អហើយចាស៕

ក៖

បាទចឹងនៅក្នុងជំនាន់ពោលពតនឹងលោកយាយបានជួបបញ្ហាដែលធំជាងគេនោះគឺលោកយាយគ្មានអ្វីនឹងសំរាប់ហូបនោះទេមែនដែលទេលោកយាយ???

ខ៖

ចាសគឺនៅក្នុងជំនាន់ពោលពតនឹងពិបាក់ជាងគេនឹងគឺគ្មានអ្វីនឹងហូបហើយខ្ញុំនឹងបានធ្វើការងារនឹងពេញកំលាំងច្រើនជាងគេហើយព្រឹកព្រលឹកឡើងគឺខ្ញុំបានទៅដើរលើចុបហើយនៅពេលដែលទៅលីចុបចឹងសឹងតែវាតែធ្វើយ៉ាងមិចគឺគេចមិនផុតទៅតែធ្វើហើយយើងនឹងត្រូវតែមានកំលាំងដើប្បីធ្វើវាចាសពីព្រោះអីយើងនឹងវាហូបបានតិចពេកវាអត់មានអីនឹងហូបនិយាយរួមទៅយើងដូចចេកគឺចេកណាំវ៉ាដែលនៅខាងមុខផ្ទះរបស់យើងចឹងហាសវាគឺយើងនឹងខំដាំហើយនៅពេលដែលយើងនឹងដាំបានហើយដល់កូនរបស់ខ្ញុំប៉ៅដោះរបស់ខ្ញុំចឹងក៏ខ្ញុំបានសុំចេកដែលវានៅខាងចុងនឹងហាសហើយនៅពេលដែលយើងកាត់ទៅអាចុងនឹងមានចេកចំនួន៤ផ្លែហើយនៅពេលដែលកាត់ទៅវាក៏បានឡើងទៅដល់អាស្និតដែលល្អហើយមាន៤ផ្លែទៀតគេក៏បានយកយើងនឹងទៅកសាងដែលតាមពិតចេកនឹងគឺជាចេកដែលយើងបានដាំដោយខ្លួនយើងហើយនៅពេលដែលចេកបានធំបានធាត់គឺយើងមិនបានស៊ីទេគ្រាន់តែយើងទៅសុំគេថាកូនរបស់ខ្ញុំវាលេងប៉ៅដោះរបស់ខ្ញុំហើយចឹងខ្ញុំសុំចេកខ្លះដើម្បីយកចេកនឹងយកទៅស្ងោរអោយកូនរបស់ខ្ញុំស៊ីចឹងយើងក៏បានសុំចេកគេចំនួន៤ផ្លែហើយនៅពេលដែ

លសុំ៥ផ្លែហើយចេកដោយមកចំនួន៥ផ្លែក៏យកយើងនឹងទៅកសាងចំនួន៥ម៉ោងដែលហើយគេបានអោយយើងនឹងបានមកផ្ទះវិញហើយបានកាន់ហើយនឹងគេបានកាត់របបរបស់យើងនឹងចំនួន១ពេលគឺមិនបានអោយយើងហូបបបរចំនួន១ព្រឹកហើយយើងនឹងបានអង្គុយទាំងពីម៉ោង១១ព្រឹកពេលដែលគេហូបរហូតដល់ម៉ោង៤ល្ងាចបានគេអោយយើងបានត្រឡប់មកផ្ទះរបស់យើងវិញគឺគេអោយនឹងអង្គុយនៅកន្លែងនឹងតែម្តងនិយាយរួមគេអោយយើងនឹងបានប្រមូលអារម្មណ៍របស់យើងនឹងហាសកុំអោយយើងបានធ្វើខុសទៀតចឹងហាសចាសនឹងហើយគឺគេបានយកយើងទៅធ្វើចឹងកុំអោយយើងនឹងបានធ្វើខុសទៀតចាសគឺអោយយើងនឹងអង្គុយនៅកន្លែងនឹងតាំងពីម៉ោង១១ព្រឹករហូតដល់ម៉ោង៤ល្ងាចបានគេអោយយើងបានត្រឡប់មកផ្ទះរបស់យើងវិញហើយគេបានអោយបបរយើងនឹងហើយគេបានកាត់បបររបស់ចំនួនពាក់កណ្តាលចាសធ្លាប់តែគេអោយបបរយើងបានចំនួន១បោយគេក៏បានកាត់អោយយើងបានតែកន្លះបោយនោះទេចាសចឹងយើងក៏ហូបបបរតែបិននឹងទៅកុំអោយគេសំលាប់យើងហាសគឺដើម្បីមានជីវិតរស់៕

ក៖
បាទចឹងនៅពេលដែលលោកយាយបានទទួលរបបតែពាក់កណ្តាលហើយលោកយាយគ្មានកំលាំងដើម្បីនឹងធ្វើការងារតើលោកយាយមានជំងឺរឺក៏ឈឺអីដែលរឺទេលោកយាយ???

ខ៖
ចាសរាល់ថ្ងៃវាឈឺដូចវាចាសគឺយើងរកទំនក់ឈឺមិនឃើញពីព្រោះអាជំងឺដែលឈឺនឹងវាអត់បានឈឺវាមានអារម្មណ៍ថាភ័យហើយនឹងខ្លាចគេនឹងយកយើងនឹងទៅសំលាប់ចោលខ្លាំងជាងចឹងហាសចឹងទៅជំងឺដូចជាជំងឺគ្រុនហើយនឹងអាជំងឺគ្រុនក្តៅអីនឹងគឺវាអត់មានចាសដូចជាចេះតែទៅរួចហើយហើយនៅពេលដែលទៅដល់ព្រៃចឹងទៅដូចជាមានស្លឹកអីចឹងទៅស្លឹកត្រួយត្ពើកនឹងក៏បេះមកណាហាសស្លឹកកក្កូរហើយនឹងស្លឹកសារម៉ៅចឹងទៅហើយនឹងត្រួយដំឡូងជ្វៀលចឹងទៅហើយនៅពេលដែលបានបេះមកក៏បានដាក់ជាមួយនឹងបបរនឹងមកហើយហាសហើយយើងនឹងក៏យកមកលៀងមកបង់ទៅចាសគឺអោយបានបបរនឹងវាបានខាប់តិចហាសចាសគឺជាមួយនឹងបបរនឹងទៅរួចហើយក៏ហូបទៅហើយជួលកាល់ក៏មានរាករួសចឹងដែលពីព្រោះអីរបស់ដែលយើងនឹងមិនត្រូវនឹងហូបចឹងហាសដូចជាត្រួយវល្លិ៍ប្រែនអីចឹងហាសគឺពិបាក់ដែលល្វរនឹងមិនបាច់ទៅហូបនោះទេគ្រាន់តែភ្លួសនឹងក៏ខ្ញុំមិនភ្លួតផងចាសគឺអត់នោះទេហូបមិនកើតទៀតទេពីព្រោះអីដែលនៅក្នុងជំនាន់នោះវាមានរស់ជាតិផ្អែមណាស់តែត្រួយសារម៉ៅនឹងគឺមិនបាច់នឹងចាំអោយឆ្អិនទេក្មួយអើយមើលតែថាមានកន្លែងណាដែលល្អអីនឹងគឺប៉ូយហើយនឹងកន្លែងតែម្តងទៅគឺទាំងឆៅនឹងទៅហើយបេះបានមួយដៃនឹងឈ្មោលញ្ញាកឈ្មោលញ្ញាកចឹងទៅហើយក៏បានរួច១ពេលចឹងទៅក៏ទៅធ្វើការងារទៀតទៅចាសពុតទ្រាក្តីបមិនទាន់ទេទំតែប៉ូងប៉ូងនឹងគឺទៅបេះអត់ហើយធ្វើដំណាំងកន្លែងណាក៏ដោយកុំតែអោយបានឃើញដើមពុតទ្រាទោះបីយ៉ាងណាក៏ដោយអោយតែបានឃើញផ្លែពុតទ្រានឹងគឺបេះមកដើម្បីយកមកបេះគ្រប់ពោះសិនដែលដើម្បីរស់រានមានជីវិតចាសគឺយ៉ាប់ខ្លាំងណាក្មួយអើយនៅក្នុងជំនាន់នឹងហាសចាសពួកក្មួយឯងមិនស្គាល់ចឹងគឺពិបាក់ណាស់

ក្មួយអើយរួចប្រសិននៅជំនាំពោលពតប្រសិនជាខុសពីខ្ញុំក៏មិនសូវបានពាក្យលំអិតចឹងដែលពីព្រោះអីមានអ្នកខ្លះគាត់ក៏បានទៅរស់នៅដែលគេថាកន្លែងល្អចឹងហាសចឹងគេមិនមានរូបមន្តដែលថារឿងអាក្រក់អាក្រក់ចឹងហាសគឺមិនបានដិតជាប់នៅក្នុងអារម្មណ៍របស់គេនោះទេចាសតែសំរាប់ខ្ញុំវិញគឺខ្ញុំទៅរស់នៅកន្លែងមានភូតឈ្លោមតែម្តងហាសចាសចឹងអារម្មណ៍របស់ខ្ញុំគឺបានដិតនៅក្នុងចិត្តរសប់ខ្ញុំតែម្តងចាសហើយនិយាយថាជំនាន់ពេលនេះហើយនឹងនៅជំនាន់ពីមុខគឺវាមានភាពខុសគ្នាឆ្ងាយខ្លាំងណាស់ចាសហើយហេតុអ្វីបានជាមកដល់ជំនាន់ពេលនេះហើយនៅតែយើងនឹងរកសូវបានស៊ីទៀតពីព្រោះអីដែលនៅក្នុងជំនាន់នោះទៀតយើងអាចតស៊ូរបានហើយក៏បានមកដល់ជំនាន់នេះយើងក៏អាចតស៊ូរទៀតបានចឹងទៅចាស៕

ក៖
បាទចឹងដែលលោកយាយមានជំងឺឈឺរាករុសតើលោកយាយមានថ្នាំអ្វីសំរាប់ព្យាបាលរឺក៏គេត្រូវបានផ្តល់ថ្នាំព្យាបាលដល់លោកយាយរឺក៏យ៉ាងមិចដែលទៅលោកយាយ???

ខ៖
ចាសគឺអត់មានទេគឺគ្មានទេគឺយើងនៅពេលដែលយើងឈឺចឹងយើងចេះតែកោសខ្យល់អីចឹងទៅហើយវាក៏បានបាត់ទៅវិញចឹងទៅចាសគ្មានថ្នាំសំរាប់ព្យាបាលមកពីណាកូនអើយមានតែថ្នាំសំរាប់តែគេដែលជាមេមេនឹងគេបានហូបចឹងទៅហើយយើងនឹងមានអីចាសគឺគ្មានទេសូមបីតែយើងនឹងបានមុចជើងរហូតមកដល់សព្វថ្ងៃនឹងមានប្រវែងណាប្រវែងអីគ្រាន់តែយើងនឹងទៅសុំតែស្ករសសំដាក់ថ្នាំយកមកបិទតែបន្តិចនឹងក៏គេបានអោយមកយើងផងជើងរបស់ខ្ញុំគឺនៅរឹងមកដល់លូវនឹងនេសនេះនេះចាសនឹងគឺមុចអំបែងកែវនឹងហាសនឹងគឺមុចអំបែងកែវនឹងដែលនៅក្នុងជំនាន់ពោលពតនឹងហាសឡើងរឹងចឹងអាចសួរប្អូនរបស់ខ្ញុំមើលខ្ញុំបានទៅសុំស្ករសគេតែគេមិនបានអោយយើងទេតែបន្តិចដើម្បីយកមកបិទជាមួយនឹងត្រួយចេកនឹងកុំអោយវាមានឈាមពេកចឹងចាសគឺគេមិនអោយយើងតែម្តងចាសនឹងយើងទៅធ្វើការផងមិនមែនយើងទៅដើរលេងនោះទេហើយនៅពេលដែលយើងទៅធ្វើការងារនឹងទៅគឺយើងដើរជាន់អំបែនកែវហើយឈាមហូលមកហើយកុំទៅលើកជើងអោយគេមើលទាំងឈាមចឹងហើយឈាមរបស់ឡើងហូលតែគេនៅតែមិនបានអោយយើងទេហើយគេបាននិយាយមកកាន់ខ្ញុំវិញថាចុះប្រសិនជាខ្ញុំអោយទៅមិត្តនារីឯងចឹងទៅតើគេគ្រាប់គ្នាបានស្អីហើយនៅពេលនឹងខ្ញុំក៏បាននិយាយថាខ្ញុំគ្រាន់តែសុំតែបន្តិចនឹងបានហើយដើម្បីយកមកបិទជាមួយនឹងត្រួយចេកតែគេបាននិយាយថាគឺអត់មានទេអោយមិត្តនារីឯងធ្វើយ៉ាងមិចបានគឺធ្វើយ៉ាងនឹងទៅចាសគឺគេដាច់ខាតគឺមិនអោយយើងនោះទេនឹងយើងឈាមមកដល់លូវនឹងផងយើងគិតមើលហើយនៅក្នុងជំនាន់ពោលពតក្មួយឯងគិតមើលមើលជើងនឹងតាំងពីឆ្នាំ១៩៧៩មកណាចាសតាំងពីឆ្នាំ១៩៧៨រឺក៏ឆ្នាំ១៩៧៩មកនឹងណាវានៅតែដកហើយនឹងមានស្នាមមកដល់សព្វថ្ងៃនឹងហើយនៅពេលដែលខ្ញុំបានឃើញស្នាមនឹងមកគឺមានភាពឈឺចាប់ខ្លាំងណាស់គ្រាន់តែសុំតែស្ករតែបន្តិចនឹងដើម្បីយកមកបិទកុំអោយហូលឈាមវាមិនបានអោយយើងផងតែចំពោះវាគឺពួកវានៅអង្គុយស៊ីផឹងហើយនឹងសើចកឹកកឹកកឹកនៅកន្លែងនឹង

គឺវាមិនព្រមអោយយើងនោះទេរួចហើយទាំងពួកវាបានឃើញយើងទាំងមានឈាមហូលទាំងថាថាក់គឺវាមិនព្រមអោយយើងនោះទេនឹងយើងទៅកាប់ដីនៅឯលើភ្នំហាសយើងនឹងខូចដែលនឹងហាសហើយនៅពេលដែលយើងទៅកាប់ហើយយើងបានឃើញប៉េងប៉ោះដែលមានស្រោមដែលមានក៏លូចឹងហាសហើយយើងក៏បានផ៊ុងជើងហើយក៏បានធ្លាក់ចូលអណ្តូងហើយក៏បានមុចជើងចឹងទៅចាសហើយអត់បានប៉េងប៉ោះនឹងស៊ីផងហើយក៏មុចជើងយើងទៀតចាស៕

កៈ
បាទចឹងអរគុណច្រើនមែនទែនលោកយាយសំរាប់ការសំភាសន៍មួយនឹងចឹងសំណួរបន្តទៀតដែលខ្ញុំចង់សួរទៅកាន់លោកយាយបន្ថែមទៀតហើយក៏ជាសំណួរចុងក្រោយរបស់លោកយាយថាតើលោកយាយមានបទពិសោធន៍ល្អល្អអ្វីខ្លះសំរាប់ជីវិតនាពេលបច្ចុប្បន្ននឹងដែលលោកយាយ??

ខៈ
ចាសបទពិសោធន៍ល្អល្អលូវនឹងបទពិសោធន៍ដែលល្អល្អគឺខ្ញុំមានអំនួតអួតខ្លួនឯងនឹងកូនរបស់ខ្ញុំបានរៀនចេះដឹងនឹងគេហាសហើយកូនបានធ្វើការងាររាជការទាំងអស់គ្នាចឹងទៅខ្ញុំគឺខ្ញុំមានអំនួតអួតខ្លួនឯងចឹងចាសបានកូនរបស់ខ្ញុំវាខំប្រឹងសិក្សាហើយនៅពេលដែលវាបានខំប្រឹងសិក្សាចឹងទៅគឺគេទាំងអស់គ្នាបានធ្វើការងារជាប៉ូលិសទាំងអស់គ្នាហើយពួកគេបានរៀនចប់ទាំងអស់គ្នាចឹងទៅហើយបានរៀនចប់បាក់ឌុបហើយហើយក៏បានអោយទៅរៀនចំនួន៤ឆ្នាំទៀតហើយនៅពេលដែលបានរៀនចប់ចំនួន៤ឆ្នាំហើយក៏កូនរបស់ខ្ញុំបានទៅប្រលងធ្វើជាប៉ូលិសបានទាំងអស់គ្នាទៀតចឹងខ្ញុំមានអំនួតអួតខ្លួនឯងត្រឹងនឹងចាសចឹងខ្ញុំមានអំនួតអួតខ្លួនឯងហើយនឹងអរគុណត្រូវថាកូនទាំងអស់បានផ្តល់អោយកំលាំងចិត្តមកដល់រូបខ្ញុំបានត្រឹមនឹងហាស៕

កៈ
បាទហ៊ឹមចឹងលោកយាយមានភាពសប្បាយរីករាយទៀតដែលរឺទេអំពីជីវិតនាពេលបច្ចុប្បន្នដែលលោកយាមាននៅសព្វថ្ងៃនឹងដែលលោកយាយ???

ខៈ
ចាសមានភាពសប្បាយរីករាយត្រង់ថាចេសមានភាពសប្បាយរីករាយថាកូនទាំងអស់គ្នាគេបានសេចក្តីសុខចឹងហាសភាពសប្បាយរីករាយនឹងសេចក្តីសុខទោះមិនបានអោយម្តាយបានហូបក៏ម្តាយមានសេចក្តីសុខដែលហើយម្តាយក៏មិនបានថាអ្វីដែលចាសអោយតែកូនឯងបានប្រពន្ធប្តីនឹងមានសេចក្តីសុខម្តាយក៏មានសេចក្តីសុខដែលគឺបិននឹងបានហើយគឺម្តាយមិនបានថាអ្វីនោះទេចាស៕

កៈ
បាទចឹងអរគុណច្រើនមែនទែនលោកយាយហើយអ្វីដែលសំខាន់សំណួរចុងក្រោយដែលខ្ញុំ

ចង់សួរទៅកាន់លោកយាយសំណួរមួយទៀតជាចុងក្រោយតើលោកយាយមានពេជ្រសំរាប់ផ្តែលផ្តាំទៅដល់កូនចៅជំនាន់ក្រោយក្រោយរបស់លោកយាយថាតើនៅពេលដែលពួកគាត់បានស្តាប់នៅពាក់ពេជ្ររបស់អំពីជំនាន់ពោលពតដែលមានភាពជីវិតដែលពិបាក់ហើយនឹងបានឆ្លងកាត់នៅភាពល្វីនហើយនឹងចុលចុតដែលនៅជំនាន់ពោលពតតើលោកយាយមានពាក្យពេជ្រអ្វីសំរាប់ផ្តែលផ្តាំទៅកាន់គាត់នៅពេលដែលពួកគាត់បានលឺសំលេងរបស់លោកយាយតើលោកយាយផ្តែលផ្តាំអ្វីខ្លះទៅកាន់គាត់បានលឺសំលេងរបស់លោកយាយដែលរឺទេលោកយាយ???

ខ៖

ចាសមានខ្ញុំសូមផ្តែលផ្តាំទៅកាន់កូនកូនហើយនឹងចៅចៅហើយនឹងក្មួយក្មួយទាំងអស់ហាសប្រសិនបើលបានលឺខ្ញុំបានសំភាសន៏នេះហើយហាសហើយប្រសិនជាបានលឺពីជំនាន់ពោលពតគឺវាមានភាពនឿយហាត់ហើយនឹងពីបាក់ហើយបានឆ្លងកាត់មុខព្រួនកន្លែងដែលបានរួចមកពីស្លាប់ហើយចឹងហើយសូមផ្តាំទៅកាន់កូនកូនហើយនឹងក្មួយក្មួយហើយនឹងយុវជនទាំងអស់ហើយនឹងកូនកូនទាំងអស់ហើយនឹងចៅចៅទាំងអស់សូមអោយជៀសផុតកុំអោយជួបនៅអំពើណាដែលមិនគួរគប្បីអោយសោះសូមអោយបានសុខទាំងអស់គ្នាណាចាសសូមអោយបានសុខទាំងអស់គ្នា៕

ក៖ បាទចឹងលោកយាយមានអ្វីច្រើនជាងនឹងទៀតដែលរឺទេលោកយាយ???

ខ៖

ចាសគឺខ្ញុំមានតែប៉ុននឹងនោទេចាសគ្រាន់តែផ្តែលផ្តាំទៅកាន់កូនកូនហើយនឹងក្មួយក្មួយហើយនឹងចៅចៅកុំអោយដើរផ្លូវខុសហើយអោយស្គាល់គុណឪពុកហើយនឹងម្តាយហើយអោយជួយអាណិតឪពុកហើយនឹងម្តាយដែលលោកយាយទាំង២ខំចិញ្ចឹមមកណាហើយខំចិញ្ចឹមតាំងពីតូចហើយអោយកូនបានទៅនឹងខំរៀនបានចេះដឹងបានធំបានធាត់តែអោយអាណិតហើយនឹងមានសេចក្តីមេតាដល់ឪពុកហើយនឹងម្តាយចឹងផងណាចាសខ្ញុំសូមផ្តែលផ្តាំតែប៉ុននឹងហើយអោយកូនបានយកចិត្តទុកដាក់ដល់ឪពុកហើយនឹងម្តាយអោយបានច្រើនច្រើនជាងខ្លួនឯងបានខ្លះទៅចាសខ្ញុំមានតែប៉ុននឹង៕

ក៖

បាទចឹងអរគុណច្រើនលោកយាយមែនទែនសំរាប់ការផ្តែលផ្តាំទៅកាន់កូនចៅក្រោយក្រោយរបស់លោកយាយហើយនៅពេលដែលពួកគាត់បានលឺសំលេងមួយនឹងសង្ឃឹមថាគាត់អាចយកពាក្យសំដីរបស់លោកយាយដែលគេបានហៅថាជាមរតរស់ដែលនៅក្នុងជំនាន់ពោលពតអោយគាត់បានលឺពាក្យពេជ្រទាំងអស់នឹងសូមអោយគាត់មានភាពភ្ញាក់រលឹកដែលលោកយាយមានភាពពិបាក់ដូចលោកយាយទៀតកុំអោយគាត់ធ្វើបាប់ឪពុកម្តាយហើយក៏សុំអោយស្រឡាញ់ឪពុកម្តាយអោយបានច្រើនជាអ្វីដែលគាត់បានមានបាទចឹងថ្ងៃនឹងគឺខ្ញុំអត់មានអ្វីច្រើនទៀតទេសំរាប់លោកយាយហើយលោកយាយមានអ្វីសំរាប់បន្ថែមទៀតដែលទេលោកយាយ???

ខ៖
ចាសគឺអត់មានប៉ុននឹងបានហើយហីកូនគ្រាន់តែផ្ដែលផ្ដាំទៅកាន់កូនកូនក្រោយក្រោយអោយពួកវាមានការចេះគោរពឪពុកហើយនឹងម្ដាយហើយនឹងអោយចេះដឹងគុណឪពុកម្ដាយហើយនឹងបងប្អូនដែលគេចាស់ទុំចឹងណាកុំអោយពួកវាមានភាពផ្ដើតផ្ដើនទៅនឹងអំពើណាដែលមិនគួរគប្បីគ្រាន់តែមានតែប៉ុននឹងសំរាប់ការផ្ដែលផ្ដាំទៅកាន់ក្មេងដែលនៅជំនាន់ក្រោយក្រោយពីព្រោះអីដែលនៅក្នុងជំនាន់ពោលពតវាបានយ៉ាប់យើនប៉ុននឹងហើយហើយមកដល់ជំនាន់នេះហើយកុំអោយឪពុកហើយនឹងម្ដាយដែលគាត់បានសល់ពីជំនានពោលពតគាត់នឿនណាយតរទៅទៀតចាសខ្ញុំមានតែប៉ុននឹងចាស៕

ក៖
បាទចឹងអរគុណច្រើនលោកយាយមែនទែនចឹងថ្ងៃនឹងក្មួយមានតែប៉ុននឹងសំរាប់ការជជែកគ្នាហើយនឹងបានពិភាគសារដែលនិយាយអំពីជំនាន់ពោលពតរឺក៏អំពីជីវប្រវត្តិរបស់លោកយាយហើយថ្ងៃនឹងក្មួយមានតែប៉ុននឹងសំរាប់លោកយាយចឹងក្មួយអរគុណច្រើនសំរាប់លោកយាយចឹងក្មួយសូមជំរាបលាណាលោកយាយបាទអរគុណច្រើនលោកយាយ៕